ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ឯកសារណែនាំបង្រៀន

ថ្នាក់ទី ៦

# បរិស្ថាន
# និង ការប្រែប្រួលអាកាសធាតុ





នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា
ឆ្នាំ ២០២២

# ឯកសារណែនាំបង្រៀន

# បរិស្ថាននិងការប្រែប្រួលអាកាសធាតុ

## ថ្នាក់ទី៦

CAMBODIA CLIMATE CHANGE ALLIANCE
Implemented by:
Funded by:
ស៊ុយអែត
Sverige

# ប្រកាស

## គណៈកម្មការគ្រប់គ្រង

ឯកឧត្តម បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា
ឯកឧត្តម បណ្ឌិត **អ៊ឹម កុច** រដ្ឋលេខាធិការ
លោកជំទាវ **ទន់ សារអ៊ុម** អនុរដ្ឋលេខាធិការ
ឯកឧត្តម **ពុត សាមិត្ត** អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ
លោក **ស៊ុន ប៊ុណ្ណា** ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

## គណៈកម្មការរៀបរៀងនិងត្រួតពិនិត្យ

លោក **វ៉ា វុទ្ធី** អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា
លោក **យិន ធី** អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

## គណៈកម្មការនិពន្ធ

លោក **សុក វុធ្ធី**
លោក **សាយ ប៉ូលីដា**

## ចងក្រងនិងរចនា

លោក **លឹម សុត្ថារិទ្ធ**

## ទីប្រឹក្សាបច្ចេកទេស

លោក បណ្ឌិត **អៀង ចន្ថា** ទីប្រឹក្សាបច្ចេកអង្គការ UNDP
លោក **អ៊ុំ សូនី** នាយកគម្រោងនៃអង្គការ UNDP

# មាតិកា

ទំព័រ

**មាតិកា** .......... i

**សេចក្ដីផ្ដើម** .......... ii

**ជំពូកទី១ បរិស្ថាន** .......... 1

មេរៀនទី១ បរិស្ថានក្នុងសាលារៀន .......... 1

មេរៀនទី២ បរិស្ថានក្នុងសហគមន៍ .......... 6

**ជំពូកទី២ កិច្ចគាំពារបរិស្ថាន** .......... 10

មេរៀនទី១ ការបំពុលទឹក .......... 10

មេរៀនទី២ ការបំពុលដី .......... 15

មេរៀនទី៣ ការបំពុលខ្យល់ .......... 20

មេរៀនទី៤ បរិយាកាសភពផែនដី .......... 25

មេរៀនទី៥ ផលប៉ះពាល់នៃការឡើងកម្ដៅលើភពផែនដី .......... 30

មេរៀនទី៦ វិធានការកាត់បន្ថយការឡើងកម្ដៅលើភពផែនដី .......... 35

**ជំពូកទី៣ ការរស់នៅដោយចីរភាព** .......... 41

មេរៀនទី១ ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ .......... 41

មេរៀនទី២ ការត្រៀមលក្ខណៈឆ្លើយតបទៅនឹងគ្រោះមហន្តរាយ ដោយធម្មជាតិ .......... 45

**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព** .......... 52

**បទានុក្រម** .......... 55

**ឯកសារយោង** .......... 58

# សេចក្ដីផ្ដើម

ឯកសារណែនាំបង្រៀនបរិស្ថាន និងការប្រែប្រួលអាកាសធាតុ សម្រាប់បឋមសិក្សាថ្នាក់ទី៤ដល់ទី៦នេះ បានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងការវិវត្តឥតឈប់ឈរទាំងផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងស្មារតីមនុស្សជាតិ។ ក្នុងន័យនេះ ការប្រែប្រួលអាកាសធាតុ គឺជាបច្ច័យមួយយ៉ាងសំខាន់ដែលមនុស្សគ្រប់រូបនៅលើផែនដីនេះ ជាពិសេសសិស្សានុសិស្សត្រូវតែយល់ដឹងនិងមានបំណិនច្បាស់លាស់ក្នុងការចូលរួមជួយបង្ការ និងការពារភពផែនដីមួយនេះ ដែលកំពុងរងនូវការកើនឡើងកំដៅជារៀងរាល់ឆ្នាំដោយសារសកម្មភាពរបស់មនុស្សនិងការរីកចម្រើនផ្នែកវិទ្យាសាស្ត្រ។

គោលបំណងសំខាន់របស់ឯកសារនេះ គឺចូលរួមលើកកម្ពស់គុណភាពអប់រំនិងជីវិតរស់នៅឱ្យកាន់តែប្រសើរឡើង ដោយពង្រឹងការផ្សារភ្ជាប់រវាងការសិក្សាទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ។ បញ្ញត្តិនៃមេរៀននីមួយៗនៃឯកកសារនេះ នឹងធ្វើឱ្យមានការផ្លាស់ប្ដូរទស្សនៈ គោលគំនិតគរុកោសល្យ និងវិធីសាស្ត្របង្រៀន ដោយប្រែក្លាយពីការបង្រៀនតែនៅក្នុងថ្នាក់ មកជាការរៀនតាមបែបសិស្សមជ្ឈមណ្ឌល ពោលគឺជាប្ដូរពីការរៀនតាមបែបផ្ទេរពុទ្ធិ មកជាការរៀនតាមបែបស្ថាបនាពុទ្ធិដោយខ្លួនឯង និងអភិវឌ្ឍសមត្ថភាព បំណិន និងដុះខាត់ឥរិយាបថសិស្សឱ្យស្រឡាញ់ការសិក្សាពេញមួយជីវិត ព្រមទាំងធានានូវគុណភាពអប់រំ។

ឯកសារណែនាំបង្រៀននេះ ណែនាំអំពីលំនាំបង្រៀនតាមបែបរិះរក និងវិធីសាស្ត្រងាយៗក្នុងការបង្រៀន ការធ្វើពិសោធន៍ ការធ្វើការងារបរិស្ថានក្នុងសាលារៀននិងក្នុងសហគមន៍ ដោយផ្ដល់អទិភាពដល់ការចូលរួមរបស់សិស្ស តាមរយៈការផ្ដល់ឱកាសច្រើនដល់សិស្សក្នុងការបញ្ចេញមតិ យោបល់ ចែករំលែកបទពិសោធន៍ និងធ្វើការរួមគ្នាយ៉ាងសកម្ម ដើម្បីបង្កើនចំណេះតាមរយៈមេរៀននីមួយៗ បង្ករិយាកាសឱ្យសិស្សកាន់តែមានចំណាប់អារម្មណ៍បន្ថែមទៀតលើមុខវិជ្ជាបរិស្ថាននិងការប្រែប្រួលអាកាសធាតុ ព្រមទាំងជំរុញការចូលរួមពីមាតាបិតា និងអ្នកអាណាព្យាបាលសិស្សក្នុងការកែលម្អបែបបទនៃការរស់នៅ ដើម្បីថែរក្សាបរិស្ថានធម្មជាតិ ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងគោរពតាមក្រមសីលធម៌បរិស្ថាន (Environmental Ethic) ផងដែរ។

ក្រោយពេលសិស្សានុសិស្សបានរៀនមុខវិជ្ជានេះ ពួកគេនឹងទទួលបានចំណេះដឹង និងបំណិនសម្រាប់ជាយានក្នុងការអភិវឌ្ឍខ្លួនឯង គ្រួសារ និងសង្គមជាតិ ជាពលរដ្ឋដែលមានទំនួលខុសត្រូវខ្ពស់ក្នុងកិច្ចថែរក្សា និងការពារបរិស្ថាន។ តាមរយៈចំណេះ ជំនាញ និងបំណិនយកទៅប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេប្រកបដោយប្រសិទ្ធភាពខ្ពស់ និងអាចបន្តការសិក្សានៅមធ្យមសិក្សា ឬសិក្សាឯកទេសវិជ្ជាជីវៈ ឬចូលរួមក្នុងជីវភាពសង្គម។

គណៈកម្មការនិពន្ធយើងខ្ញុំ សង្ឃឹមយ៉ាងមុតមាំថាឯកសារណែនាំបង្រៀនការប្រែប្រួលអាកាសធាតុ សម្រាប់បឋមសិក្សា ថ្នាក់ទី៤ដល់ទី៦នេះ នឹងផ្ដល់ឱ្យអ្នកសិក្សានូវចំណេះដឹងជាមូលដ្ឋានគ្រឹះសម្រាប់ប្រើប្រាស់គ្រប់ស្ថានភាពរស់នៅក្នុងសង្គម និងឆ្លើយតបតាមផែនការអភិវឌ្ឍសង្គម និងសកលលោក ប្រកបដោយចីរភាព៕

# ជំពូកទី១ បរិស្ថាន

## មេរៀនទី១ បរិស្ថានក្នុងសាលារៀន

(២ម៉ោង)

### ក- វត្ថុបំណង

ក្រោយពីសិក្សាមេរៀននេះចប់សិស្សអាច៖

- ពណ៌នាពីបរិស្ថាននៅក្នុងថ្នាក់រៀន
- កំណត់ថាជាកន្លែងមានបរិស្ថានស្អាត ឬកន្លែងមានបរិស្ថានមិនស្អាតនៅក្នុងថ្នាក់រៀន
- ប្រៀបធៀបកន្លែងមានបរិស្ថានស្អាតនិងកន្លែងមានបរិស្ថានមិនស្អាតក្នុងសាលារៀន
- ចូលរួមយ៉ាងសកម្មក្នុងសកម្មភាពសម្អាតបរិស្ថានក្នុងថ្នាក់រៀន សាលារៀន និងក្នុងសហគមន៍។

### ខ- សម្ភារៈ

- ហ្វឺត ខ្មៅដៃ ស្រោមដៃ កន្ត្រកដាក់សំរាម
- វីដេអូ ( https://youtube ) ថ្នាក់ ឬសាលារៀនដែលមានបរិស្ថានស្អាត
- រូបភាពដែលទាក់ទងទៅនឹងបរិស្ថានសាលារៀនស្អាត និងបរិស្ថានមិនស្អាត
- សៀវភៅសិស្សវិទ្យាសាស្ត្រថ្នាក់ទី៦ និងឯកសារផ្សេងៗ។

### គ- លំនាំនៃការបង្រៀន

| សកម្មភាពគ្រូនិងសិស្ស | សំណួរគន្លឹះ | ខ្លឹមសារ |
|---|---|---|
| ១- គ្រូនាំសិស្សឱ្យពិនិត្យមើលបរិស្ថានថ្នាក់រៀនរបស់ខ្លួន រួចឱ្យសិស្សកត់ត្រារៀងៗខ្លួននូវអ្វីដែលពួកគេបានឃើញដើម្បីឱ្យសិស្សឆ្លើយទៅនឹងសំណួរ។ | ១- ចូរពណ៌នាពីបរិស្ថាននៅក្នុងថ្នាក់រៀនរបស់ប្អូនៗ។ | ១- ថ្នាក់រៀនរបស់ខ្ញុំមាន បរិស្ថានស្អាតនៅក្នុងថ្នាក់រៀនព្រោះ៖<br>- នៅតាមទ្វារ បង្អួច តុ កៅអី គ្មានធូលី និងសំបុកពីងពាង<br>- ក្នុងថ្នាក់គ្មានសំរាម<br>- គ្មានក្លិនស្អុយ ធូលីហុយ និងសម្លេងរំខាន<br>- មានខ្យល់ចេញចូលបានល្អ<br>- មានពន្លឺគ្រប់គ្រាន់។ |
| ២- បែងចែកសិស្សជាក្រុមដើម្បី ពិភាក្សារកចម្លើយរបស់សំណួរ តាមរយៈរូបភាព និងទស្សនាវីដេអូ បរិស្ថានសាលារៀន។ | ១- ចូរពិភាក្សាពីសាលារៀនដែលមានបរិស្ថានស្អាត និងបរិស្ថានមិនស្អាត។ | ១- សាលារៀនដែលមានបរិស្ថាន ស្អាត និងបរិស្ថានមិនស្អាត៖<br>- ថ្នាក់រៀនដែលមានបរិស្ថានស្អាត ៖<br>• ទីធ្លានិងថ្នាក់រៀនគ្មានសំរាម<br>• រៀបចំកែលម្អជាប្រចាំ |

| | | |
|---|---|---|
| | | • ធ្វើអនាម័យជាប្រចាំ<br>• ធ្វើសួនផ្កាលម្អតាមដងផ្លូវចូល<br>• មានខ្យល់ និងពន្លឺគ្រប់គ្រាន់<br>• គ្មានក្លិនស្អុយ ធូលីហុយ ផ្សែងពុល និងសម្លេងរំខាន។<br>- ថ្នាក់រៀនដែលមានបរិស្ថានស្អាត ៖<br>• ទីធ្លានិងថ្នាក់រៀនសម្បូរសំរាម<br>• គ្មានការរៀបចំកែលម្អជាប្រចាំ<br>• មិនបានធ្វើអនាម័យជាប្រចាំ<br>• គ្មានសួនផ្កាលម្អតាមដងផ្លូវ<br>• គ្មានខ្យល់ និងពន្លឺគ្រប់គ្រាន់<br>• មានក្លិនស្អុយ ធូលីហុយ ផ្សែងពុល និងសម្លេងរំខាន។ |
| ៣- គ្រូដឹកនាំសិស្សបោសសម្អាត<br>• ថ្នាក់រៀន<br>• ផ្នែកខ្លះនៃទីធ្លាសាលារៀន។<br>រួចឱ្យពួកគេធ្វើការប្រៀបធៀបថ្នាក់រៀន និងធ្លាសាលារៀនមុននិងក្រោយបោសសម្អាត។ | ១- តើត្រូវធ្វើដូចម្ដេចដើម្បីឱ្យបរិស្ថានក្នុងសាលារៀនស្អាត? | ១- បរិស្ថានស្អាតសិស្សត្រូវ៖<br>- សម្អាតទីធ្លាសាលារៀនជាប្រចាំ<br>- មិនត្រូវចោលសំរាម កាកសំណល់ ឬថង់ប្លាស្ទិចពាសវាលពាសកាល និងត្រូវចោលក្នុងធុងសំរាម<br>- ត្រូវដាំដើមឈើដើម្បីយកម្លប់<br>- ធ្វើសួនផ្កាលម្អតាមមុខថ្នាក់រៀន មុខទីចាត់ការ ការិយាល័យនានានិងជុំវិញដងជាតិ និងផ្លូវចូលសាលារៀន<br>- ធ្វើសួនជីវចម្រុះ។ |
| ណែនាំសិស្សឱ្យសង្ខេបខ្លឹមសារនៃសំណួរគន្លឹះរៀងៗខ្លួន (អាចធ្វើនៅចុងម៉ោងបង្រៀន ឬនៅផ្ទះ) | | |
| នៅចុងបញ្ចប់នៃមេរៀននេះគ្រូត្រូវសួរសំណួរដូចខាងក្រោម៖(សួរ និងបូកសរុបលទ្ធផលពិភាក្សា ព្រមទាំងបន្ថែមនូវអ្វីដែលខ្វះខាតដល់សិស្ស)<br>- តើកត្តាអ្វីខ្លះដែលនាំឱ្យបរិស្ថានសាលារៀនមិនល្អ?<br>- ហេតុអ្វីបានជាត្រូវការបរិស្ថានសាលារៀនស្អាត? | | |

**សម្គាល់៖** - *គ្រូអាចប្រើសម្ភារៈ សំណួរ និងធ្វើសកម្មភាពផ្សេងៗដើម្បីសម្រេចវត្ថុបំណងនៃមេរៀន និងធ្វើឱ្យការរៀនមានភាពសកម្ម។*

- *គ្រូវាយតម្លៃការរៀននិងបង្រៀនទៅតាមការណែនាំដូចមានក្នុងកម្មវិធីសិក្សា និងឯកសារពាក់ព័ន្ធដទៃទៀត។*
- *ខ្លឹមសារមេរៀននេះចូលរួមចំណែកក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ១៣ ទី១៤ និងទី១៥។*

# រូបភាពជំនួយក្នុងការបង្រៀន

*ប្រភពរូបភាព: https://images.app.goo.gl និងសៀវភៅអប់រំស្តីពីបរិស្ថានសម្រាប់កុមារ របស់ក្រសួងបរិស្ថាន*



**រូបភាពទី១៖** បរិស្ថានថ្នាក់រៀនស្អាត និងទីធ្លាសាលារៀនបៃតង



**រូបភាពទី២៖** ការថែទាំដើមឈើ និងដំណាំក្នុងសួនបន្លែរបស់សិស្ស



*រូបភាពទី៣៖ សិស្សប្រមូលសម្អាតទីធ្លាសាលារៀន*




*រូបភាពទី៤៖ បរិស្ថានសាលារៀនស្អាត*



រូបភាពទី៥៖ គំរូតុបតែងថ្នាក់រៀនស្អាត




រូបភាពទី៦៖ គំរូតុបតែងថ្នាក់រៀនស្អាត

# មេរៀនទី២ បរិស្ថានក្នុងសហគមន៍

(១ម៉ោង)

## ក- វត្ថុបំណង

ក្រោយពីសិក្សាមេរៀននេះចប់សិស្សអាចៈ

- រៀបរាប់ពីបរិស្ថាននៅក្នុងសហគមន៍
- ពណ៌នាពីការចូលរួម និងអនុវត្តការសម្អាតបរិស្ថានក្នុងសហគមន៍
- កំណត់កន្លែងដែលមានបរិស្ថានស្អាត និងកន្លែងដែលមានបរិស្ថានមិនស្អាតនៅក្នុងសហគមន៍
- ពន្យល់ពីសារៈសំខាន់របស់បរិស្ថាននៅក្នុងសហគមន៍
- ចូលរួមយ៉ាងសកម្មក្នុងសកម្មភាពសម្អាតបរិស្ថានក្នុងលំនៅស្ថាន និងសហគមន៍។

## ខ- សម្ភារៈ

- ហ្វឹត ខ្មៅដៃស្រោមដៃ កន្ត្រកដាក់សំរាម
- រូបភាពដែលទាក់ទងទៅនឹងបរិស្ថានសហគមន៍ស្អាត
- សៀវភៅសិស្សវិទ្យាសាស្ត្រថ្នាក់ទី៦ និងឯកសារផ្សេងៗ។

## គ- លំនាំនៃការបង្រៀន

| សកម្មភាពគ្រូនិងសិស្ស | សំណួរគន្លឹះ | ខ្លឹមសារ |
|---|---|---|
| ១- ឱ្យសិស្សមើលរូបភាពៈ<br>- រូបភាពទី១ បរិស្ថានសហគមន៍ស្អាត<br>- រូបភាពទី២ បរិស្ថានសហគមន៍មានទឹកស្អាតប្រើប្រាស់ និងបរិស្ថានសហគមន៍គ្មានទឹកស្អាតប្រើប្រាស់ រួចឱ្យសិស្សកត់ត្រានូវអ្វីដែលគេបានឃើញ ដើម្បីឆ្លើយទៅនឹងសំណួរ។ | ១- ដើម្បីឱ្យបរិស្ថានក្នុងសហគមន៍បានស្អាតតើប្អូនៗត្រូវធ្វើដូចម្តេច? | ១- ដើម្បីឱ្យបរិស្ថានសហគមន៍ស្អាតៈ<br>- មិនត្រូវចោលសំរាម និងកាកសំណល់ពាសវាលពាសកាល<br>- ទុកដាក់សំរាមនិងកាកសំណល់នៅកន្លែងដែលកំណត់ដោយរដ្ឋអំណាចក្នុងមូលដ្ឋាន<br>- ដាំដើមឈើដើម្បីយកម្លប់ និងលម្អដល់បរិស្ថានក្នុងសហគមន៍<br>- មានបង្គន់អនាម័យតាមលំនៅស្ថាន តាមទីសាធារណៈ និងតាមភោជ<br>- មានប្រព័ន្ធទឹកភ្លៀងនិងទឹកសម្អុយ<br>- ត្រួតពិនិត្យកន្លែងបញ្ចេញផ្សែងពីសិប្បកម្ម និងឧស្សាហកម្ម<br>- សំណល់ត្រូវញែកតាមប្រភេទ។ |

| | | |
|---|---|---|
| ២- បែងចែកសិស្សជាក្រុមផ្សេងៗគ្នាដើម្បីគូរូប សាលារៀន វត្តអារាម ទីធ្លាផ្ទះ ទីធ្លាសាធារណៈ ផ្សារ សាលាឃុំរួចរៀបរាប់ពីបរិស្ថាននោះ។ | ១- ចូរគូររូបភាពសាលារៀន វត្តអារាម ទីធ្លាផ្ទះ ទីធ្លាសាធារណៈ ផ្សារ សាលាឃុំនៅក្នុងសហគមន៍ រួចរៀបរាប់ពីបរិស្ថាននោះ។ | ១- ខ្លឹមសារអាស្រ័យទៅនឹងរូបភាពដែលសិស្សបានគូរ។ |
| ៣- គ្រូនាំសិស្សដើររើសសំរាមក្នុងសាលារៀន ឬក្នុងសហគមន៍ដែលនៅជិតសាលារៀនបំផុត វត្តអារាម ទីធ្លាសាធារណៈ ផ្សារ សាលាឃុំ...។ | ១- បើសហគមន៍មានបរិស្ថានស្អាត តើប្អូនៗគិតថាមានផលប្រយោជន៍អ្វីខ្លះចំពោះប្រជាជនដែលរស់នៅក្នុងសហគមន៍? | ១- បើសហគមន៍មានបរិស្ថានស្អាតនោះ ប្រជាជនដែលរស់នៅក្នុងសហគមន៍នឹងទទួលបាន៖<br>- ការងារធ្វើ និងមានមុខរបរច្រើន<br>- គ្មានចំណាកស្រុក<br>- ទទួលបានសុខភាពល្អគ្រប់ៗគ្នា<br>- សេដ្ឋកិច្ចគ្រួសារកើនឡើង។ |
| ណែនាំសិស្សឱ្យសង្ខេបខ្លឹមសារនៃសំណួរគន្លឹះរៀងៗខ្លួន (អាចធ្វើនៅចុងម៉ោងបង្រៀន ឬនៅផ្ទះ) | | |
| នៅចុងបញ្ចប់នៃមេរៀននេះគ្រូត្រូវសួរសំណួរដូចខាងក្រោម៖(សួរ និងបូកសរុបលទ្ធផលពិភាក្សា ព្រមទាំងបន្ថែមនូវអ្វីដែលខ្វះខាតដល់សិស្ស)<br>- តើមូលហេតុអ្វីខ្លះដែលជាកត្តានាំឱ្យបរិស្ថាននៅក្នុងសហគមន៍មិនល្អ?<br>- ចូរប្អូនរៀបរាប់អំពីផលប៉ះពាល់ដែលបណ្តាលមកពីសហគមន៍មិនល្អ។ | | |

**សម្គាល់៖** - *គ្រូអាចប្រើសម្ភារៈ សំណួរ និងធ្វើសកម្មភាពផ្សេងៗដើម្បីសម្រេចវត្ថុបំណងនៃមេរៀន និងធ្វើឱ្យការរៀនមានភាពសកម្ម។*

- *គ្រូវាយតម្លៃការរៀននិងបង្រៀនទៅតាមការណែនាំដូចមានក្នុងកម្មវិធីសិក្សានិងឯកសារពាក់ព័ន្ធដទៃទៀត*
- *ខ្លឹមសារមេរៀននេះចូលរួមចំណែកក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី១៣ ទី១៤ និងទី១៥។*

# រូបភាពជំនួយក្នុងការបង្រៀន

*ប្រភពរូបភាព:* https://images.app.goo.gl




***រូបភាពទី១៖*** *បរិស្ថានស្អាត សហគមន៍ស្អាត*




***រូបភាពទី២៖*** *បរិស្ថានសហគមន៍មានទឹកស្អាតប្រើប្រាស់ និងគ្មានទឹកស្អាតប្រើប្រាស់*



**រូបភាពទី៣៖** ការចូលរួមសម្អាតបរិស្ថានសហគមន៍



**រូបភាពទី៤៖** ការចូលរួមទុកដាក់ និងញែកសំរាមតាមប្រភេទ

# ជំពូកទី២ កិច្ចគាំពារបរិស្ថាន

## មេរៀនទី១ ការបំពុលទឹក

(១ម៉ោង)

### ក- វត្ថុបំណង

ក្រោយពីសិក្សាមេរៀននេះចប់សិស្សអាច៖

- រៀបរាប់បានពីមូលហេតុនៃការបំពុលទឹក
- ពណ៌នាបានពីផលប៉ះពាល់ដែលបណ្តាលមកពីការប្រើប្រាស់ទឹកពុល
- ប្រៀបធៀបបានពីទឹកដែលរងការបំពុល និងទឹកដែលមិនរងការបំពុល
- កំណត់បានពីវិធីដើម្បីកាត់បន្ថយការបំពុលទឹក
- ចូលរួមអនុវត្ត និងផ្សព្វផ្សាយពីវិធីកាត់បន្ថយការបំពុលទឹកនៅក្នុងសហគមន៍
- បណ្តុះស្មារតីចូលរួមថែរក្សាកុំមានការបំពុលទឹកនៅក្នុងសហគមន៍។

### ខ- សម្ភារៈ

- ហ្វីត ខ្មៅដៃស្រោមដៃ កន្រ្តកដាក់សំរាម
- រូបភាពដែលទាក់ទងទៅនឹងការបំពុលទឹក
- សៀវភៅសិស្សវិទ្យាសាស្រ្តថ្នាក់ទី៦ និងឯកសារផ្សេងៗ។

### គ- លំនាំនៃការបង្រៀន

| សកម្មភាពគ្រូនិងសិស្ស | សំណួរគន្លឹះ | ខ្លឹមសារ |
|---|---|---|
| ១- គ្រូណែនាំសិស្សទៅមើលប្រភពទឹក ថ្លុកទឹកស្អុយនិងពិនិត្យមើលការបង្ហូរទឹកស្អុយចេញពីបន្ទប់ទឹក ដែលមានក្នុងបរិវេណសាលារៀន ឬក្នុងសហគមន៍ដែរឬទេ? រួចឱ្យសិស្សកត់ត្រារៀងៗខ្លួននូវអ្វីៗដែលគេបានឃើញ។ | ១- ដូចម្តេចដែលហៅថាការបំពុលទឹក? | ១- ការបំពុលទឹក អាចត្រូវបានគេឱ្យនិយមន័យច្រើនយ៉ាងផ្សេងៗពីគ្នា។ ជាទូទៅ ការបំពុលទឹកគឺជាការធ្វើឱ្យកង្វក់ដល់ទឹក នៅពេលដែលសារធាតុបំពុលនានាបានហូរចូលទៅក្នុងប្រភពទឹក។ |
| ២- បង្ហាញរូបភាពដែលបណ្តាលឱ្យមានការបំពុលទឹក៖<br>- រូបភាពទី១ សំណល់រាវ<br>- រូបភាពទី២ ថ្នាំពុលកសិកម្ម<br>- រូបភាពទី៣ កន្លែងចោលសំរាម<br>- រូបភាពទី៤ កសិដ្ឋានចិញ្ចឹមសត្វ។ | ១- ចូររាប់ពីមូលហេតុដែលនាំឱ្យប្រភពទឹករងការបំពុល? | ១- ការបំពុលទឹកភាគច្រើនបណ្តាលមកពីសំណល់ពីរោងចក្រឧស្សាហកម្ម ថ្នាំពុលកសិកម្ម កន្លែងចោលសំរាម កសិដ្ឋានចិញ្ចឹមសត្វ និងសំណល់រាវតាមផ្ទះ។ សកម្មភាពដែលនាំឱ្យប្រភពទឹករងការបំពុលគឺបង្កឡើងដោយកត្តាមនុស្ស។ |

<table>
<tr><td rowspan="2">រួចបែងចែកសិស្សជាក្រុមផ្សេងៗគ្នា ឱ្យសិស្សពិភាក្សារកចម្លើយសម្រាប់សំណួរគន្លឹះ។</td><td>២- ចូររៀបរាប់ពីផលប៉ះពាល់បណ្ដាលមកពីការប្រើប្រាស់ទឹករងការបំពុល។</td><td>២- ការប្រើប្រាស់ទឹករងការបំពុលបណ្ដាលឱ្យមានផលប៉ះពាល់ដូចជា៖<br>- បង្ករជំងឺ (កើតរោគសើរស្បែក រាករូស អាសន្នរោគ...)<br>- ខ្វះទឹកប្រើប្រាស់ទៅអនាគត<br>- ខូចគុណភាពទឹកទាំងស្រុង។</td></tr>
<tr><td>៣- ចូរកំណត់ពីវិធីដើម្បីកាត់បន្ថយការបំពុលប្រភពទឹក។</td><td>៣- ដើម្បីការពារប្រភពទឹកកុំឱ្យមានការបំពុល៖<br>- មិនសង់បង្គន់ក្បែរប្រភពទឹក<br>- មិនសង់ប្រព័ន្ធបង្ហូរទឹកស្អុយចូលក្នុងប្រភពទឹក<br>- មិនចោលសំរាមផ្សេងៗក្នុងទឹក<br>- មិនប្រើប្រាស់ថ្នាំគីមីក្នុងវិស័យកសិកម្ម<br>- ធ្វើគម្របនិងរបងព័ទ្ធជុំវិញប្រភពទឹកដែលប្រើប្រាស់ប្រចាំថ្ងៃ<br>- ត្រួតពិនិត្យគុណភាពជាប្រចាំ។</td></tr>
<tr><td colspan="3">ណែនាំសិស្សឱ្យសង្ខេបខ្លឹមសារនៃសំណួរគន្លឹះរៀងៗខ្លួន (អាចធ្វើនៅចុងម៉ោងបង្រៀន ឬនៅផ្ទះ)</td></tr>
<tr><td colspan="3">នៅចុងបញ្ចប់នៃមេរៀននេះគ្រូត្រូវសួរសំណួរដូចខាងក្រោម៖(សួរ និងបូកសរុបលទ្ធផលពិភាក្សា ព្រមទាំងបន្ថែមនូវអ្វីដែលខ្វះខាតដល់សិស្ស)<br>- ចូររៀបរាប់ពីផលប៉ះពាល់ដែលបណ្ដាលមកពីការប្រើប្រាស់ទឹករងការបំពុល។<br>- ដើម្បីកាត់បន្ថយការបំពុលទឹកនៅក្នុងសហគមន៍ តើប្អូនៗត្រូវធ្វើអ្វីខ្លះ?</td></tr>
</table>

**សម្គាល់៖** - *គ្រូអាចប្រើសម្ភារៈ សំណួរ និងធ្វើសកម្មភាពផ្សេងៗដើម្បីសម្រេចវត្ថុបំណងនៃមេរៀន និងធ្វើឱ្យការរៀនមានភាពសកម្ម។*

- *គ្រូវាយតម្លៃការរៀននិងបង្រៀនទៅតាមការណែនាំដូចមានក្នុងកម្មវិធីសិក្សានិងឯកសារពាក់ព័ន្ធដទៃទៀត។*
- *ខ្លឹមសារមេរៀននេះចូលរួមចំណែកក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៣ ទី៦ ទី១២ និងទី១៤។*

# រូបភាពជំនួយក្នុងការបង្រៀន

*ប្រភពរូបភាព: [https://images.app.goo.gl](https://images.app.goo.gl)*



**រូបភាពទី១៖** សំណល់រាវហូរចូលក្នុងប្រភពទឹក



**រូបភាពទី២៖** សំណល់ថ្នាំពុលកសិកម្ម



**រូបភាពទី៣៖** ថ្នាំពុលកសិកម្មលើដំណាំស្រូវ



**រូបភាពទី៤៖** សំរាមនៅតាមដងផ្លូវនៅក្រៅធុងសំរាម



***រូបភាពទី៥៖*** *កសិដ្ឋានចិញ្ចឹមសត្វជាប្រភពនៃការបំពុលទឹក*



***រូបភាពទី៦៖*** *សំណល់តាមផ្ទះហូរចូលក្នុងប្រភពទឹក*

# មេរៀនទី២ ការបំពុលដី

(១ម៉ោង)

## ក- វត្ថុបំណង

ក្រោយពីសិក្សាមេរៀននេះចប់សិស្សអាចៈ

- រៀបរាប់បានពីមូលហេតុនៃបំពុលដី និងកត្តាដែលនាំឱ្យការបំពុលដី
- ពណ៌នាបានពីផលប៉ះពាល់ដែលបណ្តាលមកពីការបំពុលដី
- ប្រៀបធៀបបានពីដីដែលរងការបំពុល និងដីដែលមិនរងការបំពុល
- កំណត់បានពីវិធីដើម្បីកាត់បន្ថយការបំពុលដី
- បណ្តុះស្មារតីចូលរួមថែដីកុំមានការបំពុលនៅក្នុងសហគមន៍
- ចូលរួមអនុវត្ត និងផ្សព្វផ្សាយពីវិធីកាត់បន្ថយការបំពុលដីនៅក្នុងសហគមន៍។

## ខ- សម្ភារៈ

- រូបភាពដែលទាក់ទងទៅនឹងការបំពុលដី
- សៀវភៅសិស្សវិទ្យាសាស្រ្តថ្នាក់ទី៦ និងឯកសារផ្សេងៗ។

## គ- លំនាំនៃការបង្រៀន

| សកម្មភាពគ្រូនិងសិស្ស | សំណួរគន្លឹះ | ខ្លឹមសារ |
|---|---|---|
| ១- បង្ហាញរូបភាពពីការបំពុលដីៈ<br>រូបភាពទី១ ការកប់សំរាមក្នុងដី<br>រូបភាពទី២ ការទុកដាក់សំរាម មិនបានត្រឹមត្រូវៈ<br>- រូបភាពទី៣ ការប្រើប្រាស់ជីគីមីកសិកម្ម<br>- រូបភាពទី៤ ថ្នាំសម្លាប់សត្វល្អិត<br>- រូបភាពទី៥ កសិដ្ឋានចិញ្ចឹមសត្វ<br>រួចឱ្យសិស្សកត់ត្រារៀងៗខ្លួន ដើម្បីឆ្លើយនឹងសំណួរ។ | ១- ដូចម្តេចដែលហៅថាការបំពុលដី? | ១- ការបំពុលដី គឺជាការដែលធ្វើឱ្យដីដែលដាំដុះទទួលបានភោគផលច្រើន ក្លាយទៅជាដីដែលដែលដាំដុះទទួលបានភោគផលតិចទៅរហូតដល់លែងទទួលបានភោគផលសោះ (បាត់បង់ដីគុណភាពដី)។ |
| ២- បែងចែកសិស្សជាក្រុមផ្សេងៗគ្នា ឱ្យសិស្សពិភាក្សារកចម្លើយ សម្រាប់សំណួរគន្លឹះ។ | ១- ចូររៀបរាប់បានពីមូលហេតុនៃបំពុលដី? | ១- មូលហេតុដែលនាំឱ្យមានការកំពុលដីៈ<br>- ការចោលកាកសំណល់មិនត្រឹមត្រូវ<br>- ការប្រើប្រាស់ជីគីមីក្នុងកសិកម្ម<br>- ថ្នាំសម្លាប់សត្វល្អិត<br>- កសិដ្ឋានចិញ្ចឹមសត្វ<br>- ការកើនកម្តៅនៃភពផែនដី។ |

| | | |
|---|---|---|
| | ២- ការប្រើប្រាស់ដីដែលរងការបំពុលដី តើមានផលប៉ះពាល់ដូចម្តេចខ្លះ? | ២- ការប្រើប្រាស់ដីដែលរងការបំពុមានផលប៉ះពាល់ ៖<br>- ទិន្នផលកសិកម្មថយចុះ<br>- បាត់ប្រាក់ចំណូលគ្រួសារ និងជាតិ<br>- ប្រជាជនត្រូវធ្វើចំណាកស្រុកទៅរកកន្លែងថ្មីដែលដីមានជីជាតិ<br>- ក្រសួងកសិកម្មត្រូវចំណាយថវិកា និងពេលវេលាច្រើនដើម្បីស្តារដីដែលរងការបំពុលឡើងវិញ។ |
| | ៣- ដើម្បីកាត់បន្ថយការបំពុលដី តើប្អូនៗត្រូវមានវិធីធានការដូចម្តេចខ្លះ? | ៣- ដើម្បីកាត់បន្ថយការបំពុលដីយើងត្រូវមានវិធីធានការ៖<br>- ចេះបែងចែកកាកសំណល់<br>- ចោលកាកសំណល់តាមប្រភេទ<br>- មិនប្រើប្រាស់ជីគីមីក្នុងវិស័យកសិកម្មជាដាច់ខាត<br>- ទីតាំងកសិដ្ឋានចិញ្ចឹមសត្វសមស្រប<br>- ទប់ស្កាត់ការកើនកម្តៅនៃភពផែនដី។ |
| ណែនាំសិស្សឱ្យសង្ខេបខ្លឹមសារនៃសំណួរគន្លឹះរៀងៗខ្លួន (អាចធ្វើនៅចុងម៉ោងបង្រៀន ឬនៅផ្ទះ) | | |
| នៅចុងបញ្ចប់នៃមេរៀននេះគ្រូត្រូវសួរសំណួរដូចខាងក្រោម៖(សួរ និងបូកសរុបលទ្ធផលពិភាក្សា ព្រមទាំងបន្ថែមនូវអ្វីដែលខ្វះខាតដល់សិស្ស)<br>- តើកត្តាអ្វីខ្លះដែលនាំឱ្យមានការបំពុលដី?<br>- ចូររៀបរាប់ពីការកាត់បន្ថយការបំពុលដីនៅក្នុងសាលារៀនឬសហគមន៍? | | |

**សម្គាល់៖** - *គ្រូអាចប្រើសម្ភារៈ ការប្រើប្រាស់សំណួរ និងធ្វើសកម្មភាពផ្សេងៗដើម្បីសម្រេចវត្ថុបំណងនៃមេរៀន និងធ្វើឱ្យការរៀនមានភាពសកម្ម។*
- *គ្រូវាយតម្លៃការរៀននិងបង្រៀនទៅតាមការណែនាំដូចមានក្នុងកម្មវិធីសិក្សានិងឯកសារពាក់ព័ន្ធដទៃទៀត*
- *ខ្លឹមសារមេរៀននេះចូលរួមចំណែកក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៣ ទី១២ ទី១៤ និងទី១៥។*

# រូបភាពជំនួយក្នុងការបង្រៀន

*ប្រភពរូបភាព:* https://images.app.goo.gl



***រូបភាពទី១៖*** *ការកប់សំរាមក្នុងដី*




***រូបភាពទី២៖*** *ការទុកដាក់សំរាមមិនបានត្រឹមត្រូវ*




***រូបភាពទី៣៖*** *ការប្រើប្រាស់ជីគីមីកសិកម្ម*




***រូបភាពទី៤៖*** *ជីគីមីកសិកម្ម*



*រូបភាពទី៥៖ ថ្នាំពុលសម្លាប់សត្វល្អិត*



*រូបភាពទី៦៖ កសិដ្ឋានចិញ្ចឹមសត្វ*

# មេរៀនទី៣ ការបំពុលខ្យល់

(១ម៉ោង)

## ក- វត្ថុបំណង

ក្រោយពីសិក្សាមេរៀននេះចប់សិស្សអាចៈ

- រៀបរាប់បានពីប្រភពនៃបំពុលខ្យល់
- ពណ៌នាបានពីប្រភេទជំងឺដែលបណ្ដាលមកពីការបំពុលខ្យល់
- កំណត់បានពីផលប៉ះពាល់ដែលបណ្ដាលមកពីការបំពុលខ្យល់
- បណ្ដុះស្មារតីចូលរួមធ្វើសកម្មភាពណាដែលមិនបំពុលខ្យល់
- អប់រំ និងផ្សព្វផ្សាយ នៅក្នុងសហគមន៍អំពីខ្យល់អាកាសដែលរងការបំពុល។

## ខ- សម្ភារៈ

- រូបភាពដែលទាក់ទងទៅនឹងការបំពុលខ្យល់
- សៀវភៅសិស្សវិទ្យាសាស្ត្រថ្នាក់ទី៦ និងឯកសារផ្សេងៗ។

## គ- លំនាំនៃការបង្រៀន

| សកម្មភាពគ្រូនិងសិស្ស | សំណួរគន្លឹះ | ខ្លឹមសារ |
|---|---|---|
| ១- គ្រូដឹកនាំសិស្សមើលរូបភាពដែលទាក់ទងនឹងការបំពុលខ្យល់តាមរយៈសកម្មភាពមនុស្សដូចជាៈ<br>- រូបភាពទី១ ផ្សែងចេញពីរោងចក្រឧស្សាហកម្ម<br>- រូបភាពទី២ ការដុតសំរាម<br>- រូបភាពទី៣ ផ្សែងចេញពីម៉ូតូឡាន<br>- រូបភាពទី៤ ភ្លើងឆេះព្រៃនិងបន្ទុះភ្នំភ្លើង។<br>រួចឱ្យពួកគេកត់ត្រារៀងៗខ្លួននូវអ្វីៗដែលគេបានសង្កេតរូបភាពឆ្លើយទៅនឹងសំណួរគន្លឹះ។ | ១- ដូចម្ដេចដែលហៅថាការបំពុលខ្យល់ ? | ១- ការបំពុលខ្យល់ គឺជាបន្ថែមសមាសធាតុពុលផ្សេងៗចូលទៅក្នុងខ្យល់។ |
| | ២- ចូររៀបរាប់បានពីមូលហេតុនៃបំពុលខ្យល់ ? | ២- មូលហេតុសំខាន់ៗដែលនាំឱ្យមានការបំពុលខ្យល់គឺៈ<br>- សកម្មភាពមនុស្សៈ<br>✓ ផ្សែងចេញពីរោងចក្រ<br>✓ ការដុតសំរាម<br>✓ ប្រើប្រាស់សារធាតុគីមី<br>✓ ផ្សែងចេញពីម៉ូតូឡាន<br>✓ សំណង់អគារកើនឡើងខ្ពស់។<br>- គ្រោះធម្មជាតិៈ<br>✓ បន្ទុះភ្នំភ្លើង<br>✓ ភ្លើងឆេះព្រៃ។ |
| ២- បែងចែកសិស្សជាក្រុមផ្សេងៗគ្នា ដើម្បីឱ្យក្រុមសិស្សពិភាក្សារកចម្លើយរបស់សំណួរគន្លឹះ។ | ១- ការប្រើប្រាស់ខ្យល់ដែលរងការបំពុលខ្យល់ តើមានផលប៉ះពាល់ដូចម្ដេចខ្លះ? | ១- ការប្រើប្រាស់ខ្យល់ដែលរងការបំពុលខ្យល់មានផលប៉ះពាល់ដូចជាៈ<br>- ជំងឺផ្លូវដង្ហើម<br>- ជំងឺភ្នែក<br>- ជំងឺរលាកស្បែក |

| | | |
|---|---|---|
| | | - ខូចគុណភាពខ្យល់។ |
| | ២- ដើម្បីកាត់បន្ថយការបំពុលខ្យល់ តើប្អូនៗត្រូវមានវិធីធានការដូចម្ដេចខ្លះ? | ២- ដើម្បីកាត់បន្ថយការបំពុលខ្យល់ត្រូវមានវិធីធានការដូចជា៖<br>- ចូលរួមការពារ ថែរក្សា និងដាំដើមឈើឡើងវិញ<br>- ប្រើប្រាស់ប្រេងដែលមានជាតិសំណតិចបំផុត<br>- កាត់បន្ថយការប្រើប្រាស់ថាមពលផូស៊ីលឥន្ធនៈ<br>- ជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញ<br>- ចូលរួមសន្សំសំចៃអគ្គិសនី និងទឹក<br>- កុំដុតកាកសំណល់ក្រៅឡ។ |

| |
|---|
| ណែនាំសិស្សឱ្យសង្ខេបខ្លឹមសារនៃសំណួរគន្លឹះរៀងៗខ្លួន (អាចធ្វើនៅចុងម៉ោងបង្រៀន ឬនៅផ្ទះ) |
| នៅចុងបញ្ចប់នៃមេរៀននេះគ្រូត្រូវសួរសំណួរដូចខាងក្រោម៖( សួរ និងបូកសរុបលទ្ធផលពិភាក្សា ព្រមទាំងបន្ថែមនូវអ្វីដែលខ្វះខាតដល់សិស្ស )<br>- បើខ្យល់នៅក្នុងសាលារៀន ឬសហគមន៍ប្អូនទទួលរងការបំពុលដោយសារមូលហេតុអ្វី?<br>- ចូររៀបរាប់ពីការកាត់បន្ថយការបំពុលខ្យល់នៅក្នុងសាលារៀនឬសហគមន៍។ |

**សម្គាល់៖** - *គ្រូអាចប្រើសម្ភារៈ សំណួរ និងធ្វើសកម្មភាពផ្សេងៗដើម្បីសម្រេចវត្ថុបំណងនៃមេរៀន និងធ្វើឱ្យការរៀនមានភាពសកម្ម។*

- *គ្រូវាយតម្លៃការរៀននិងបង្រៀនទៅតាមការណែនាំដូចមានក្នុងកម្មវិធីសិក្សានិងឯកសារពាក់ព័ន្ធដទៃទៀត*
- *ខ្លឹមសារមេរៀននេះចូលរួមចំណែកក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៣ ទី១២ និងទី១៥។*

# រូបភាពជំនួយក្នុងការបង្រៀន

*ប្រភពរូបភាព:* https://images.app.goo.gl



**រូបភាពទី១៖** ផ្សែងចេញពីរោងចក្រឧស្សាហកម្ម



**រូបភាពទី២៖** ការដុតសំរាម



រូបភាពទី៖ ផ្សែងចេញពីរថយន្ត



រូបភាពទី៤៖ ផ្សែងចេញពីម៉ូតូ



រូបភាពទី៣៖ បន្ទុះភ្នំភ្លើង



រូបភាពទី៤៖ ភ្លើងឆេះព្រៃ

# មេរៀនទី៤ បរិយាកាសភពផែនដី

(២ម៉ោង)

## ក- វត្ថុបំណង

ក្រោយពីសិក្សាមេរៀននេះចប់សិស្សអាច៖

- រៀបរាប់បានពីសមាសភាពបរិយាកាស
- ពណ៌នាបានពីកម្ដៅនៃភពផែនដី
- កំណត់បានពីការកើនឡើងកម្ដៅនៃភពផែនដី
- ចូលរួមរាល់សកម្មភាពដែលការពារភពផែនដីកុំឱ្យឡើងកម្ដៅ
- ចូលរួមអប់រំ និងផ្សព្វផ្សាយពីការកើនឡើងនៃភពផែនដី។

## ខ- សម្ភារៈ

- រូបភាពដែលទាក់ទងទៅនឹងបរិយាកាសភពផែនដី
- សៀវភៅសិស្សវិទ្យាសាស្ត្រថ្នាក់ទី៦ និងឯកសារផ្សេងៗ។

## គ- លំនាំនៃការបង្រៀន

| សកម្មភាពគ្រូនិងសិស្ស | សំណួរគន្លឹះ | ខ្លឹមសារ |
|---|---|---|
| ១- គ្រូឱ្យសិស្សទស្សនាវីដេអូ (https:// youtube) បរិយាកាសភពផែនដី រួចឱ្យសិស្សកត់ត្រារៀងៗខ្លួននូវអ្វីៗដែលគេបានឃើញ ដើម្បីឆ្លើយទៅនឹងសំណួរ។ | ១- អ្វីទៅជាបរិយាកាសភពផែនដី? | ១- បរិយាកាសភពផែនដី គឺជាលំហខ្យល់ (ស្រទាប់ឧស្ម័ន) ច្រើនជាន់ដែលព័ទ្ធជុំវិញភពផែនដី។ |
| ២- គ្រូចែករូបភាព៖<br>- រូបភាពទី១ សមាសធាតុនៃបរិយាកាសផែនដី<br>- រូបភាពទី២ ស្រទាប់បរិយាកាសភពផែនដី<br>- រូបភាពទី៣ កម្ដៅនៃភពផែនដី<br>- រូបភាពទី៤ ការកើនកម្ដៅភពផែនដី។<br><br>រួចបែងចែកសិស្សជាក្រុម ឱ្យសិស្សកត់ត្រារៀងៗខ្លួននូវអ្វីដែលគេបានឃើញ ដើម្បីឆ្លើយទៅនឹងសំណួរ។ | ១- ចូររាប់ពីសមាសបរិយាកាសភពផែនដី? | ២- សមាសធាតុបរិយាកាសផែនដីរួមមាន៖<br>- អាសូត ($N_2$) ៧៨%<br>- អុកស៊ីសែន ($O_2$) ២១%<br>- ឧស្ម័នមួយចំនួនទៀត ១% |
| | ២- គេចែកបរិយាកាសភពផែនដីចែកជាប៉ុន្មាន? អ្វីខ្លះ? | ២- គេចែកបរិយាកាសភពផែនដីចែកជា៥ស្រទាប់៖<br>- ស្រទាប់អាកាសរចល់ (ពី០គ.ម ទៅ១៧គ.ម)<br>- ស្រទាប់អាកាសស្ងប់ (ពី១៧គ.ម ទៅ៤៨គ.ម)<br>- ស្រទាប់អាកាសកណ្ដាល(ពី៤៨គ.ម ទៅ៨០គ.ម) |

| | | |
|---|---|---|
| | | - ស្រទាប់អាកាសកម្តៅ (ពី៨០គ.ម ទៅ៥៥០គ.ម)<br>- ស្រទាប់អាកាសក្រៅ (ពី៥៥គ.ម ឡើងទៅ)។ |
| | ៣- អ្វីទៅជាកម្តៅនៃភពផែនដី? | ៣- ជាទូទៅនៅក្នុងស្រទាប់អាកាសរចល់ត្រូវមានកំហាប់ឧស្ម័នផលផ្ទះកញ្ចក់ ដើម្បីជួយរក្សាឱ្យមានលំនឹងតាមធម្មជាតិដែលសីតុណ្ហភាពមធ្យមនៃភពផែនដីនៅត្រឹមតែ១៦អង្សាសេ ដែលអាចទ្រទ្រង់ជីវិតនៅលើភពផែនដីរស់បាន។ លំនាំបែបនេះ គេឱ្យឈ្មោះថា « *ផលផ្ទះកញ្ចក់ (Greenhouse Effect)* » ដែលជាបាតុភូតធម្មជាតិ ដែលធានាកម្តៅនៃភពផែនដី។ |
| | ៤- ដូចម្តេចដែលហៅថាការកើនឡើងនៃកម្តៅនៃភពផែនដី ? | ៤- ដែលហៅថាការកើនឡើងនៃកម្តៅនៃភពផែនដី គឺជាកើនឡើងនៃឧស្ម័នផ្ទះកញ្ចក់នៅក្នុងស្រទាប់អាកាសរចល់។ |
| | ៥- បើប្អូនៗដឹងថាភពផែនដីកំពុងកើនកម្តៅ តើប្អូនៗត្រូវរួមចំណែកអ្វីខ្លះ ? | ៥- ដើម្បីចូលរួមការពារកុំឱ្យភពផែនដីកើនកម្តៅយើងត្រូវ៖<br>- ផ្សព្វផ្សាយ អប់រំពីការកើនឡើងកម្តៅនៃភពផែនដី<br>- ដាំ ការពារ និងថែរក្សាដើមឈើ<br>- ប្រើប្រាស់ថាមពលគ្មានជាតិសំណ<br>- មិនប្រើប្រាស់ឥន្ធនៈផូស៊ីល<br>- ប្រើប្រាស់ថាមពលកកើតឡើងវិញ<br>- ចេះសន្សំសំចៃទឹក និងភ្លើង<br>- ថែរក្សា និងបង្កើនប្រភពទឹក<br>- កាកសំណល់ត្រូវញែកទៅតាមប្រភេទ។<br>- អនុវត្តទៅតាមគោលការណ៍5R គឺ៖<br>✓ បដិសេធការប្រើប្រាស់<br>✓ កាត់បន្ថយ |

| | | |
|---|---|---|
| | | ✓ ប្រើប្រាស់ឡើងវិញ<br>✓ កែច្នៃឡើងវិញ<br>✓ រំលឹកអ្នកដទៃ៤ចំណុចខាងលើ។ |
| ណែនាំសិស្សឱ្យសង្ខេបខ្លឹមសារនៃសំណួរគន្លឹះរៀងៗខ្លួន (អាចធ្វើនៅចុងម៉ោងបង្រៀន ឬនៅផ្ទះ) | | |
| នៅចុងបញ្ចប់នៃមេរៀននេះគ្រូត្រូវសួរសំណួរដូចខាងក្រោម៖( សួរ និងបូកសរុបលទ្ធផលពិភាក្សា ព្រមទាំងបន្ថែមនូវអ្វីដែលខ្វះខាតដល់សិស្ស )<br>- ហេតុអ្វីបានជាភពផែនដីមានការកើនឡើងនូវកម្ដៅ?<br>- ចូររៀបរាប់ពីការកាត់បន្ថយការកើនកម្ដៅនៃភពផែនដី។ | | |

**សម្គាល់៖** - *គ្រូអាចប្រើសម្ភារៈ សំណួរ និងធ្វើសកម្មភាពផ្សេងៗដើម្បីសម្រេចវត្ថុបំណងនៃមេរៀន និងធ្វើឱ្យការរៀនមានភាពសកម្ម។*

- *គ្រូវាយតម្លៃការរៀននិងបង្រៀនទៅតាមការណែនាំដូចមានក្នុងកម្មវិធីសិក្សានិងឯកសារពាក់ព័ន្ធដទៃទៀត*
- *ខ្លឹមសារមេរៀននេះចូលរួមចំណែកក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៣ ១៣ និង ១៥។*

# រូបភាពជំនួយក្នុងការបង្រៀន

*ប្រភពរូបភាព: https://images.app.goo.gl*




*រូបភាពទី១៖ សមាសធាតុនៃបរិយាកាសភពផែនដី*




*រូបភាពទី២៖ ស្រទាប់ទាំង៥នៃបរិយាកាសភពផែនដី*




***រូបភាពទី៣៖*** *ដំណើរការផលផ្ទះកញ្ចក់*




***រូបភាពទី៤៖*** *ការកើនឡើងកម្តៅភពផែនដី*

# មេរៀនទី៥ ផលប៉ះពាល់នៃការឡើងកម្តៅលើភពផែនដី

(២ម៉ោង)

## ក- វត្ថុបំណង

ក្រោយពីសិក្សាមេរៀននេះចប់សិស្សអាចៈ

- រៀបរាប់ពីផលប៉ះពាល់ដល់សុខភាពដែលបណ្តាលពីការកើនកម្តៅលើភពផែនដី
- ពណ៌នាពីផលប៉ះពាល់បណ្តាលមកពីការកើនកម្តៅលើភពផែនដីទៅលើកសិកម្ម
- កំណត់បានពីវិធានការកាត់បន្ថយនៃផលប៉ះពាល់ដល់ការអប់រំ និងកសិកម្ម
- បណ្តុះស្មារតីចូលរួមសកម្មភាពដែលកាត់បន្ថយការកើនឡើងកម្តៅ
- ចូលរួមថែរក្សា ការពារ និងដាំដើមឈើឡើងវិញនៅតាមផ្ទះ សាលារៀន និងសហគមន៍។

## ខ- សម្ភារៈ

- កុំព្យូទ័រ ម៉ាស៊ីនបញ្ចាំង (LED)
- រូបភាពដែលទាក់ទងទៅនឹងផលប៉ះពាល់ការកើនកម្តៅនៃភពផែនដី
- សៀវភៅសិស្សវិទ្យាសាស្ត្រថ្នាក់ទី៦ និងឯកសារផ្សេងៗ។

## គ- លំនាំនៃការបង្រៀន

| សកម្មភាពគ្រូនិងសិស្ស | សំណួរគន្លឹះ | ខ្លឹមសារ |
|---|---|---|
| ១- នាំសិស្សទស្សនាវីដេអូ (https://youtube) ផលប៉ះពាល់ពីការកើនកម្តៅនៃភពផែនដីទៅលើសុខភាព ការអប់រំ និង វិស័យកសិកម្ម រួចឱ្យសិស្សកត់ត្រារៀងៗខ្លួននូវអ្វីៗដែលគេបានទស្សនាដើម្បីឆ្លុះបញ្ចាំងមកក្នុងសហគមន៍ដែលគេរស់នៅ។ | ១- នៅក្នុងសហគមន៍របស់ប្អូនមានទទួលរងនូវផលប៉ះពាល់ដែរឬទេ? | ១- នៅក្នុងសហគមន៍របស់ខ្ញុំមានទទួលរងនូវផលប៉ះពាល់នេះដែរ។ |
| ២- បែងចែកសិស្សជាក្រុម ដើម្បីពិភាក្សាលើសំណួរតាមរយៈរូបភាព ដែលទាក់ទងនឹងផលប៉ះពាល់ពីការកើនកម្តៅនៃភពផែនដីទៅលើសុខភាព ការអប់រំ និង វិស័យកសិកម្ម។ | ១- ចូរធ្វើការរៀបរាប់ពីផលប៉ះពាល់ដល់សុខភាពប្រជាជននៅក្នុងសហគមន៍របស់ប្អូន? | ១- ការកើនកម្តៅភពផែនដីមានផលប៉ះពាល់ដល់សុខភាពប្រជាជននៅក្នុងសហគមន៍ខ្ញុំរួមមានៈ<br>- ជំងឺសើរស្បែក<br>- ជំងឺរលាកផ្លូវដង្ហើម<br>- ជំងឺភ្នែក<br>- ខាតបង់ពេលវេលា និងថវិកា<br>- រដ្ឋចំណាយថវិកាជាតិច្រើន។ |

| | | |
|---|---|---|
| | ២- ចូរធ្វើការរៀបរាប់ពីផលប៉ះពាល់នៃការអប់រំនៅក្នុងសាលារៀនរបស់ប្អូន? | ២- ការកើនកម្ដៅភពផែនដីមានផលប៉ះពាល់ដល់ការអប់រំនៅក្នុងសាលារៀនខ្ញុំរួមមាន៖<br>- ប្រឈមនឹងការបិទសាលា<br>- ភ្លៀងច្រើនពេកលិចសាលា<br>- មានខ្យល់ព្យុះ<br>- មានទឹកជំនាន់<br>- បរវេសនកាលតូចត្រូវច្រើនថ្ងៃ<br>- ចំនួនសិស្សានុសិស្សថយចុះ<br>- គុណភាពសិក្សាធ្លាក់ចុះ។ |
| | ៣- ចូរធ្វើការរៀបរាប់ពីផលប៉ះពាល់ទៅលើវិស័យកសិកម្មនៅក្នុងសហគមន៍របស់ប្អូន? | ៣- ការកើនកម្ដៅភពផែនដីមានផលប៉ះពាល់ទៅលើវិស័យកសិកម្មនៅក្នុងសហគមន៍របស់ខ្ញុំរួមមាន៖<br>- រដូវប្រាំងអូសបន្លាយវែង<br>- មានគ្រោះរាំងស្ងួត<br>- មានទឹកជំនាន់<br>- ផ្ទៃដីផលិតកម្មគ្មានជីជាតិ<br>- ប្រជាកសិករចំណាយកម្លាំង ពេលវេលា និងថវិកាច្រើនបានផលតិច<br>- គុណភាពផលិតផលថយចុះ<br>- ទិន្នផលថយចុះ។ |
| ណែនាំសិស្សឱ្យសង្ខេបខ្លឹមសារនៃសំណួរគន្លឹះរៀងៗខ្លួន (អាចធ្វើនៅចុងម៉ោងបង្រៀន ឬនៅផ្ទះ) | | |
| នៅចុងបញ្ចប់នៃមេរៀននេះគ្រូត្រូវសួរសំណួរដូចខាងក្រោម៖ សួរ និងបូកសរុបលទ្ធផលពិភាក្សា ព្រមទាំងបន្ថែមនូវអ្វីដែលខ្វះខាតដល់សិស្ស។<br>- តើប្អូនៗត្រូវធ្វើដូចម្ដេចខ្លះ ដើម្បីកាត់បន្ថយផលប៉ះពាល់ដែលបណ្ដាលពីការកើនឡើងកម្ដៅនៃភពផែនដីទៅលើសុខភាព ការអប់រំ និងកសិកម្មនៅក្នុងសហគមន៍របស់។<br>- ហេតុអ្វីបានជាត្រូវការធ្វើសកម្មភាព ដលើម្បីកាត់បន្ថយកម្ដៅភពផែនដី? | | |

**សម្គាល់៖** - *គ្រូអាចប្រើសម្ភារៈ សំណួរ និងធ្វើសកម្មភាពផ្សេងៗដើម្បីសម្រេចវត្ថុបំណងនៃមេរៀន និងធ្វើឱ្យការរៀនមានភាពសកម្ម។*

- *គ្រូវាយតម្លៃការរៀននិងបង្រៀនទៅតាមការណែនាំដូចមានក្នុងកម្មវិធីសិក្សានិងឯកសារពាក់ព័ន្ធដទៃទៀត*
- *ខ្លឹមសារមេរៀននេះចូលរួមចំណែកក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៣ ទី១៣ និងទី១៥។*

# រូបភាពជំនួយក្នុងការបង្រៀន

*ប្រភពរូបភាព: [https://images.app.goo.gl](https://images.app.goo.gl)*



***រូបភាពទី១៖** ធ្វើឱ្យមនុស្សក្តៅស្អុតហួតហែងអស់កម្លាំង*



***រូបភាពទី២៖** កុមារងាយកើតជំងឺផ្សេងៗ*



*រូបភាពទី៣៖ ខ្យល់ព្យុះខូចខាតសាលារៀន*




*រូបភាពទី៤៖ គ្រោះទឹកជំនន់លិចផ្លូវ និងសហគមន៍*



***រូបភាពទី៥៖*** *គ្រោះទឹកជំនន់ទៅលើវិស័យកសិកម្ម*



***រូបភាពទី៦៖*** *គ្រោះរាំងស្ងួតទៅលើវិស័យកសិកម្ម*

# មេរៀនទី៦ វិធានការកាត់បន្ថយការឡើងកម្តៅលើផែនដី

(២ម៉ោង)

## ក- វត្ថុបំណង

ក្រោយការបណ្តុះបណ្តាលនេះសិស្សនឹងអាចៈ

- ពណ៌នាពីការប្រើប្រាស់ថាមពលកកើតឡើងវិញ
- កំណត់ពីវិធីប្រើប្រាស់ថាមពលអគ្គិសនី និងទឹកដោយសន្សំសំចៃ
- ញែកសំរាមឱ្យបានត្រឹមត្រូវប្រើប្រាស់ឡើងវិញ និងការកែច្នៃជាថ្មី
- ចូលរួមសន្សំសំចៃថាមពលអគ្គិសនី និងសន្សំសំចៃទឹក
- ចូលរួមថែរក្សា ការពារ និងដាំដើមឈើឡើងវិញនៅក្នុងសហគមន៍។

## ខ- សម្ភារៈ

- រូបភាពដែលទាក់ទងទៅនឹងវិធានការកាត់បន្ថយការឡើងកម្តៅលើភពផែនដី
- សៀវភៅសិស្សវិទ្យាសាស្ត្រថ្នាក់ទី៦ និងឯកសារផ្សេងៗ។

## គ- លំនាំនៃការបង្រៀន

| សកម្មភាពគ្រូនិងសិស្ស | សំណួរគន្លឹះ | ខ្លឹមសារ |
|---|---|---|
| ១- នាំសិស្សទស្សនាវីដេអូ (https:// youtube) ការប្រែប្រួលអាកាសធាតុនៅលើផែនដី រួចឱ្យសិស្សកត់ត្រារៀងៗខ្លួននូវអ្វីៗដែលគេបានទស្សនាដើម្បីចម្លើយសំណួរ។ | ១- តើមូលហេតុអ្វីដែលបណ្តាលឱ្យមានការប្រែប្រួលអាកាសធាតុ? | ១- ការប្រែប្រួលអាកាសធាតុ កើតឡើងពីការកើនឡើងឧស្ម័នផ្ទះកញ្ចក់នៅក្នុងបរិយាកាស។ ឧស្ម័នផ្ទះកញ្ចក់រាំងខ្ទប់កាំរស្មីក្រហមអាល់ហ្វាឱ្យភាយចេញពីបរិយាកាសផែនដីបានដែលធ្វើឱ្យផែនដីឡើងកម្តៅ។<br>- កត្តាចម្បងបណ្តាលឱ្យមានការកើនឡើងកម្តៅនៃភពផែនដីគឺសកម្មភាពមនុស្ស ដូចជាការដុតប្រេងនូនៈ សម្រាប់ជាថាមពល ចំហេះពីរថយន្តផ្សែងចេញពីរោងចក្រ បានធ្វើឱ្យកើនឡើងឧស្ម័នផ្ទះកញ្ចក់<br>- ការកាប់ព្រៃឈើធ្វើឱ្យការស្រូបយកឧស្ម័នកាបូនិច ($CO_2$) ដែលជាឧស្ម័នផ្ទះកញ្ចក់មួយដ៏ចំបងថយចុះ នេះធ្វើឱ្យឧស្ម័នកាបូនិចក្នុងបរិយាកាសកើនឡើង។ |

<table>
<tr>
<td>២- បែងចែកសិស្សជាក្រុម និងចែករូបភាពដែលទាក់ទងទៅនឹងការកាត់បន្ថយការកើនកម្ដៅនៃភពផែនដី ដើម្បីពិភាក្សារកចម្លើយទៅតាមក្រុមនីមួយៗ។</td>
<td>១- ចូររៀបរាប់ពីការកាត់បន្ថយការកើនកម្ដៅនៃភពផែនដី។</td>
<td>១- ដើម្បីកាត់បន្ថយការកើនកម្ដៅនៃភពផែនដីយើងត្រូវ៖<br>- ផ្សព្វផ្សាយ អប់រំពីការកើនឡើងកម្ដៅនៃភពផែនដី<br>- ដាំ ការពារ និងថែរក្សាដើមឈើ<br>- ប្រើប្រាស់ថាមពលដែលគ្មានជាតិសំណ<br>- កាត់បន្ថយការប្រើប្រាស់ឥន្ធនៈផូស៊ីល<br>- ចូលរួមប្រើប្រាស់ថាមពលដែលកកើតឡើងវិញ<br>- ចេះសន្សំសំចៃទឹក និងភ្លើង<br>- ថែរក្សា និងបង្កើនប្រភពទឹក<br>- កាកសំណល់ត្រូវញែកទៅតាមប្រភេទ<br>- អនុវត្តទៅតាមគោលការណ៍5R ៖<br>✓ បដិសេធការប្រើប្រាស់<br>✓ កាត់បន្ថយ<br>✓ ប្រើប្រាស់ឡើងវិញ<br>✓ កែច្នៃឡើងវិញ<br>✓ រំលឹកអ្នកដទៃ៤ចំណុចខាងលើ។</td>
</tr>
<tr>
<td colspan="3">៣- គ្រូនាំសិស្សធ្វើសកម្មភាពពិសោធន៍<br>ដំណើរការកកើតផលផ្ទះកញ្ចក់<br>- សំណួរគន្លឹះ<br>តើសីតុណ្ហភាពនៅខាងក្នុងដបកែវ និខាងក្រៅដបខុសគ្នាស្មើគ្នាឬទេ? ហេតុអ្វី?<br>- សម្ភារៈ<br>✓ ដបកែវឬប្លាស្ទិក១ដែលមានគំរប<br>✓ ទែម៉ូម៉ែត្រ២។<br>- ដំណើរការពិសោធន៍<br>✓ ដំបូងដាក់ទែម៉ូម៉ែត្រ១ចូលទៅកែវរួចបិតគំរប<br>✓ កត់ត្រាសីតុណ្ហភាព និងពេលវេលា នៃទែម៉ូម៉ែត្រទាំង២<br>✓ រួចយកទែម៉ូមែត្រទាំង២ទៅដាក់ក្រោមកម្ដៅថ្ងៃ<br>✓ ចាប់ផ្ដើមកំណត់ពេលវេលារយៈពេល ៣នាទីទៅកត់ត្រាសីតុណ្ហភាពនៃទែម៉ូមែត្រទាំង២ម្ដង<br>✓ កត់ត្រារយៈពេល៥ដង</td>
</tr>
</table>

| |
|---|
| - ឱ្យសិស្សបូកសរុបលទ្ធផល ដោយគូរក្រាបបន្ទាត់តាមទិន្នន័យដែលស្រង់បាន<br>- ឡើងបង្ហាញលទ្ធផលតាមក្រុម<br>- គ្រូសំយោគ សង្ខេបមេរៀន។ |
| ណែនាំសិស្សឱ្យសង្ខេបខ្លឹមសារនៃសំណួរគន្លឹះរៀងៗខ្លួន (អាចធ្វើនៅចុងម៉ោងបង្រៀន ឬនៅផ្ទះ) |
| នៅចុងបញ្ចប់នៃមេរៀននេះគ្រូត្រូវសួរសំណួរដូចខាងក្រោម៖(សួរ និងបូកសរុបលទ្ធផលពិភាក្សា ព្រមទាំងបន្ថែមនូវអ្វីដែលខ្វះខាតដល់សិស្ស)<br>- ចូររៀបរាប់ពីការប្រើប្រាស់ថាមពល ដើម្បីកាត់បន្ថយការកើនកម្តៅនៃភពផែនដី។<br>- បន្ថែម៖ ការដាំព្រៃ ការរក្សាប្រភពទឹក និងវាលភក់ធម្មជាតិ។ |

**សម្គាល់៖** - *គ្រូអាចប្រើសម្ភារៈ សំណួរ និងធ្វើសកម្មភាពផ្សេងៗដើម្បីសម្រេចវត្ថុបំណងនៃមេរៀន និងធ្វើឱ្យការរៀនមានភាពសកម្ម។*

- *គ្រូវាយតម្លៃការរៀននិងបង្រៀនទៅតាមការណែនាំដូចមានក្នុងកម្មវិធីសិក្សានិងឯកសារពាក់ព័ន្ធដទៃទៀត*
- *ខ្លឹមសារមេរៀននេះចូលរួមចំណែកក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៣ ទី១៣ និងទី១៥។*

# រូបភាពជំនួយក្នុងការបង្រៀន

*ប្រភពរូបភាព: https://images.app.goo.gl*




***រូបភាពទី១៖*** *ដំណើរការកកើតឥទ្ធិពលផ្ទះកញ្ចក់*



***រូបភាពទី២៖*** *ការសន្សំសំចៃទឹក*



***រូបភាពទី៣៖*** *ការសន្សំសំចៃអគ្គិសនី*



***រូបភាពទី៤៖*** *ការប្រើប្រាស់ថាមពលវារីអគ្គិសនី*



**រូបភាពទី៥៖** ការប្រើប្រាស់ថាមពលព្រះអាទិត្យ



**រូបភាពទី៦៖** ការដាំដើមឈើឡើងវិញ ដើម្បីកាត់បន្ថយការកើនកម្ដៅនៃភពផែនដី

# ជំពូកទី៣ ការរស់នៅដោយចីរភាព

## មេរៀនទី១ ការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ

(២ម៉ោង)

### ក- វត្ថុបំណង

ក្រោយការបណ្តុះបណ្តាលនេះសិស្សនឹងអាចៈ

- រៀបរាប់បានពីវិធានការបន្សុំាការប្រែប្រួលអាកាសធាតុមកលើសុខភាព ការអប់រំ និងកសិកម្ម
- អនុវត្តពីការបន្សុំាការប្រែប្រួលអាកាសធាតុមកលើសុខភាព ការអប់រំ និងកសិកម្ម
- ចូលរួមសកម្មភាពបន្សុំាការប្រែប្រួលអាកាសធាតុមកលើសុខភាព អប់រំ និងកសិកម្មក្នុងសហគមន៍។

### ខ- សម្ភារៈ

- រូបភាពដែលទាក់ទងទៅនឹងការបន្សុំាប្រែប្រួលអាកាសធាតុ
- វីដេអូ ការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុទៅលើវិស័យកសិកម្ម
- សៀវភៅវិទ្យាសាស្ត្រថ្នាក់ទី៦ និងឯកសារផ្សេងៗទៀត។

### គ- លំនាំនៃការបង្រៀន

| សកម្មភាពគ្រូនិងសិស្ស | សំណួរគន្លឹះ | ខ្លឹមសារ |
|---|---|---|
| ១- ឱ្យសិស្សទស្សនាវីដេអូ ការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុរួចឱ្យសិស្សកត់ត្រារៀងៗខ្លួននូវអ្វីៗដែលគេបានទស្សនា ដើម្បីឆ្លើយទៅនឹងសំណួរ។ | ១- ដូចម្តេចទៅដែលហៅថាការបន្សុំា? | ១- ការបន្សុំាគឺជាការសម្របខ្លួនទៅនឹងមជ្ឈដ្ឋានរស់នៅ (រាំងស្ងួត ទឹកជំនន់ ខ្យល់ព្យុះ ការប្រែប្រួលអាកាសធាតុ...)។ |
| ២- បែងចែកសិស្សជាក្រុម ដើម្បីពិភាក្សា រួចចែករូបភាពដែលទាក់ទងនឹងការបន្សុំាសុខភាព ការអប់រំ និងវិស័យកសិកម្មទៅនឹងការប្រែប្រួលអាកាសធាតុ ។<br>- ក្រុមទី១៖ សំណួរទី១<br>- ក្រុមទី២៖ សំណួរទី២<br>- ក្រុមទី៣៖ សំណួរទី៣។ | ១- ដើម្បីឱ្យសុខភាពសុំាទៅនឹងការប្រែប្រួលអាកាសធាតុ តើប្អូនៗត្រូវធ្វើដូចម្តេច? | ១- ដើម្បីឱ្យសុខភាពសុំាទៅនឹងការប្រែប្រួលអាកាសធាតុ៖<br>- ញុំាទឹកឱ្យបានច្រើន<br>- ងូតទឹកឱ្យបានញឹកញាប់<br>- ញុំាអាហារដែលធ្វើឱ្យរាងកាយសម្របទៅនឹងអាកាសធាតុ<br>- ស្លៀកពាក់ឱ្យសមស្របទៅនឹងការប្រែប្រួលអាកាសធាតុ<br>- ត្រូវព្យាយាមស្ថិតនៅនឹងកន្លែងដូចជានៅក្នុងលំនៅស្ថាន ឬម្លប់<br>- ពេលធ្វើដំណើរត្រូវចេះជ្រើសរើសពេលវេលាដែលសមស្រប<br>- ឧស្សាហ៍ទៅពិនិត្យសុខភាព។ |

<table>
<tr><td rowspan="2"></td><td>២- ដើម្បីឱ្យវិស័យកសិកម្ម (ដំណាំស្រូវ) ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ តើប្អូនៗត្រូវធ្វើដូចម្ដេច?</td><td>២- ដើម្បីឱ្យវិស័យកសិកម្មស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ៖<br>- ញ៉ាំទឹកឱ្យបានច្រើន<br>- ងូតទឹកឱ្យបានញឹកញាប់<br>- ញ៉ាំអាហារដែលធ្វើឱ្យរាងកាយសម្របទៅនឹងអាកាសធាតុ<br>- ស្លៀកពាក់ឱ្យសមស្របទៅនឹងការប្រែប្រួលអាកាសធាតុ<br>- ត្រូវព្យាយាមស្ថិតនៅនឹងកន្លែងដូចជានៅក្នុងលំនៅស្ថាន ឬម្លប់<br>- ពេលធ្វើដំណើរត្រូវចេះជ្រើស រើសពេលវេលាដែលសមស្រប<br>- ឧស្សាហ៍ទៅពិនិត្យសុខភាព។</td></tr>
<tr><td>៣- ដើម្បីឱ្យការសិក្សាអប់រំដំណើរការជាធម្មតានៅពេលមានការប្រែប្រួលអាកាសធាតុ តើប្អូនៗត្រូវចូលរួមធ្វើអ្វីខ្លះ?</td><td>៣- ដើម្បីឱ្យការសិក្សាអប់រំដំណើរការជាធម្មតានៅពេលមានការប្រែប្រួលអាកាសធាតុយើងត្រូវ៖<br>- ដាំដើមឈើតាមដងផ្លូវ និងទីធ្លាសាលារៀន ដើម្បីយកម្លប់បង្កើតប្រភពទឹក និងប្រព័ន្ធទឹកសម្រាប់ប្រើប្រាស់<br>- ធ្វើសួនផ្កាលម្អតាមផ្លូវចូល ដងទង់ជាតិ និងថ្នាក់រៀន<br>- សំណង់អគារមានខ្យល់ចេញចូលបានល្អមានពិដានជញ្ជាំងត្រូវមានអ៊ីសូឡង់និងសង់បណ្ដោយថ្ងៃ។</td></tr>
<tr><td colspan="3">ណែនាំសិស្សឱ្យសង្ខេបខ្លឹមសារនៃសំណួរគន្លឹះរៀងៗខ្លួន (អាចធ្វើនៅចុងម៉ោងបង្រៀន ឬនៅផ្ទះ)</td></tr>
<tr><td colspan="3">នៅចុងបញ្ចប់នៃមេរៀននេះគ្រូត្រូវសួរសំណួរដូចខាងក្រោម៖ សួរ និងបូកសរុបលទ្ធផលពិភាក្សា ព្រមទាំងបន្ថែមនូវអ្វីដែលខ្វះខាតដល់សិស្ស។<br>- ដើម្បីត្រៀមទប់ទល់ទៅនឹងការប្រែប្រួលអាកាសធាតុ តើប្អូនត្រូវធ្វើអ្វីខ្លះ?<br>- ចូរសរសេរផែនការសាលារៀនឱ្យស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ?</td></tr>
</table>

**សម្គាល់៖** - *គ្រូអាចប្រើសម្ភារៈ សំណួរ និងធ្វើសកម្មភាពផ្សេងៗដើម្បីសម្រេចវត្ថុបំណងនៃមេរៀន និងធ្វើឱ្យការរៀនមានភាពសកម្ម។*

- *គ្រូវាយតម្លៃការរៀននិងបង្រៀនទៅតាមការណែនាំដូចមានក្នុងកម្មវិធីសិក្សានិងឯកសារពាក់ព័ន្ធដទៃទៀត*
- *ខ្លឹមសារមេរៀននេះចូលរួមចំណែកក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៣ ទី១៣ និងទី១៥។*

# រូបភាពជំនួយក្នុងការបង្រៀន

*ប្រភពរូបភាព:* *https://images.app.goo.gl*





*រូបភាពទី១៖ ការថែទាំ និងប្រមូលផលស្រូវ*




***រូបភាពទី២៖*** *កត្តាដែលនាំឱ្យកើនកម្តៅភពផែនដី ផលប៉ះពាល់ដល់វិស័យ និងការចូលរួមកាត់បន្ថយ*



***រូបភាពទី៣៖*** *ការដាំដើមឈើឡើងវិញ*

# មេរៀនទី២ ការត្រៀមលក្ខណៈឆ្លើយតបទៅនឹងគ្រោះមហន្តរាយដោយធម្មជាតិ

(២ម៉ោង)

## ក- វត្ថុបំណង

ក្រោយសិក្សាមេរៀននេះចប់សិស្សនឹងអាចៈ

- រៀបរាប់បានពីគ្រោះមហន្តរាយធម្មជាតិដែលអាចនឹងកើតមាននៅក្នុងសហគមន៍
- កំណត់បានពីផែនការឆ្លើយតបទៅនឹងគ្រោះមហន្តរាយធម្មជាតិ
- អនុវត្តផែនការឆ្លើយតបទៅនឹងគ្រោះមហន្តរាយធម្មជាតិ។

## ខ- សម្ភារៈ

- រូបភាពដែលទាក់ទងទៅនឹងគ្រោះមហន្តរាយដោយធម្មជាតិ
- សៀវភៅវិទ្យាសាស្ត្រថ្នាក់ទី៦ និងឯកសារផ្សេងៗទៀត។

## គ- លំនាំនៃការបង្រៀន

| សកម្មភាពគ្រូនិងសិស្ស | សំណួរគន្លឹះ | ខ្លឹមសារ |
|---|---|---|
| ១- ឱ្យសិស្សមើលរូបភាពៈ<br>- រូបភាពទី១ គ្រោះទឹកជំនន់<br>- រូបភាពទី២ គ្រោះរាំងស្ងួត<br>- រូបភាពទី៣ ខ្យល់ព្យុះ។<br>រួចឱ្យសិស្សកត់ត្រារៀងៗខ្លួនដើម្បីឆ្លើយនិងសំណួរ។ | ១- ដូចម្ដេចដែលហៅថាគ្រោះមហន្តរាយធម្មជាតិ? | ១- គ្រោះមហន្តរាយធម្មជាតិ ជាគ្រោះមហន្តរាយដែលកើតឡើងដោយធម្មជាតិមានដូចជាៈ<br>- គ្រោះទឹកជំនន់<br>- គ្រោះរាំងស្ងួត<br>- ខ្យល់ព្យុះ<br>- ខ្យល់កន្ត្រាក់ ជាដើម។ |
| ២- ឱ្យសិស្សទស្សនាវីដេអូ ឬរូបភាពពីការឆ្លើយតបទៅនឹងគ្រោះទឹកជំនន់ រាំងស្ងួត ខ្យល់ព្យុះ រួចបែងចែកសិស្សជាក្រុមផ្សេងៗគ្នា ឱ្យសិស្សពិភាក្សាសំណួរដែលគ្រូចែកឱ្យតាមក្រុមនីមួយៗ។<br>- ក្រុមទី១ៈ ចូរសរសេរផែនការដើម្បីឆ្លើយតបទៅនឹងគ្រោះទឹកជំនន់។<br>- ក្រុមទី២ៈ ចូរសរសេរផែនការដើម្បីឆ្លើយតបទៅនឹងគ្រោះរាំងស្ងួត។ | ២- ចូរសរសេរផែនការដើម្បីឆ្លើយតបទៅនឹងគ្រោះទឹកជំនន់។ | ២- ដើម្បីឆ្លើយតបទៅនឹងគ្រោះទឹកជំនន់ យើងត្រូវ ៖<br>- ចូលរួមការពារ ថែរក្សា និងដាំដើមឈើឡើងវិញ<br>- ចូលរួមអនុវត្តរាល់សកម្មភាពដែលមិននាំឱ្យមានការប្រែប្រួលអាកាស ធាតុ ដូចជា ៖<br>✓ ផ្សព្វផ្សាយ អប់រំពីការកើនឡើងកម្ដៅនៃភពផែនដី<br>✓ ប្រើប្រាស់ថាមពលគ្មានជាតិសំណ<br>✓ មិនប្រើប្រាស់ឥន្ធនៈផូស៊ីល |

| | | |
|---|---|---|
| - ក្រុមទី៣៖ ចូរសរសេរផែនការដើម្បីឆ្លើយតបទៅនឹងគ្រោះខ្យល់ព្យុះ។ | | ✓ ប្រើប្រាស់ថាមពលកកើតឡើងវិញ<br>✓ ចេះសន្សំសំចៃទឹក និងភ្លើង<br>✓ ថែរក្សា និងបង្កើនប្រភពទឹក។<br>- សំណល់ត្រូវញែកទៅតាមប្រភេទ<br>- អនុវត្តតាមគោលការណ៍5R គឺ៖<br>✓ បដិសេធការប្រើប្រាស់<br>✓ កាត់បន្ថយ<br>✓ ប្រើប្រាស់ឡើងវិញ<br>✓ កែច្នៃឡើងវិញ<br>✓ រំលឹកអ្នកដទៃ៤ចំណុចខាងលើ។<br>- លើកទំនប់ការពារសហគមន៍<br>- រកទីទួលសុវត្ថិភាពពេលទឹកជំនន់<br>- ត្រៀមគ្រឿងឧបភោគនិងបរិភោគ<br>- ត្រៀមថ្នាំថ្នាំពេទ្យ។ |
| | ៣- ចូរសរសេរផែនការដើម្បីឆ្លើយតបទៅនឹងគ្រោះរាំងស្ងួត។ | ៣- ដើម្បីឆ្លើយតបទៅនឹងគ្រោះរាំងស្ងួត យើងត្រូវ ៖<br>- ចូលរួមការពារ ថែរក្សា និងដាំដើមឈើឡើងវិញ<br>- ចូលរួម និងអនុវត្តរាល់សកម្មភាព មិននាំឱ្យមានការប្រែប្រួលអាកាស ធាតុ ដូចជា៖<br>✓ ប្រើប្រាស់ថាមពលគ្មានជាតិសំណ<br>✓ មិនប្រើប្រាស់ឥន្ធនៈ ផូស៊ីល<br>✓ ប្រើប្រាស់ថាមពលកកើតឡើងវិញ<br>✓ ចេះសន្សំសំចៃទឹក និងភ្លើង<br>✓ ថែរក្សា និងបង្កើនប្រភពទឹក<br>- សំណល់ត្រូវញែកទៅតាមប្រភេទ<br>- អនុវត្តតាមគោលការណ៍5R គឺ៖<br>✓បដិសេធការប្រើប្រាស់ |

| | | |
|---|---|---|
| | | ✓កាត់បន្ថយ<br>✓ប្រើប្រាស់ឡើងវិញ<br>✓កែច្នៃឡើងវិញ<br>✓រំលឹកអ្នកដទៃ ៤ចំណុចខាងលើ។<br>- ថែរក្សា ស្តារ និងបង្កើតធារាសាស្ត្រ<br>- ថែរក្សា ស្តារ និងបង្កើតប្រភពទឹក<br>- បម្រុងទុកគ្រឿងឧបភោគ បរិភោគនិងថ្នាំពេទ្យ។ |
| | ៤- ចូរសរសេរផែនការដើម្បីឆ្លើយតបទៅនឹងខ្យល់ព្យុះ។ | ៤- ដើម្បីឆ្លើយតបទៅនឹងគ្រោះខ្យល់ព្យុះ យើងត្រូវ ៖<br>- ត្រូវតាមដានការព្យាករណ៍អាកាសធាតុជាប្រចាំ<br>- ចូលរួមការពារ ថែរក្សា និងដាំដើមឈើឡើងវិញ<br>- ចូលរួម និងអនុវត្តរាល់សកម្មភាព មិននាំឱ្យមានការប្រែប្រួលអាកាសធាតុ ដូចជា៖<br>✓ ប្រើប្រាស់ថាមពលគ្មានជាតិសំណ<br>✓ មិនប្រើប្រាស់ឥន្ធនៈផូស៊ីល<br>✓ ប្រើប្រាស់ថាមពលកកើតឡើងវិញ<br>✓ ចេះសន្សំសំចៃទឹក និងភ្លើង<br>- ថែរក្សា និងបង្កើនប្រភពទឹក<br>- សំណល់ត្រូវញែកទៅតាមប្រភេទ<br>- អនុវត្តតាមគោលការណ៍5R គឺ៖<br>✓ បដិសេធការប្រើប្រាស់<br>✓ កាត់បន្ថយ<br>✓ ប្រើប្រាស់ឡើងវិញ<br>✓ កែច្នៃឡើងវិញ<br>✓ រំលឹកអ្នកដទៃ៤ចំណុចខាងលើ។ |

| | | |
|---|---|---|
| | | - បម្រុងទុកគ្រឿងឧបភោគ បរិភោគនិងថ្នាំពេទ្យ<br>- ប្រសិនបើដឹងមុនត្រូវទៅរកកន្លែងដែលមានសុវត្ថិភាព។ |
| ណែនាំសិស្សឱ្យសង្ខេបខ្លឹមសារនៃសំណួរគន្លឹះរៀងៗខ្លួន (អាចធ្វើនៅចុងម៉ោងបង្រៀន ឬនៅផ្ទះ) | | |
| នៅចុងបញ្ចប់នៃមេរៀននេះគ្រូត្រូវសួរសំណួរដូចខាងក្រោម៖ (សួរ និងបូកសរុបលទ្ធផលពិភាក្សា ព្រមទាំងបន្ថែមនូវអ្វីដែលខ្វះខាតដល់សិស្ស)<br>- តើនៅពេលមានគ្រោះមហន្តរាយដោយធម្មជាតិយើងត្រូវត្រៀមអ្វីខ្លះ?<br>- ចូរប្អូនរៀបរាប់អំពីផលប៉ះពាល់ដែលបណ្ដាលគ្រោះមហន្តរាយដោយធម្មជាតិ (ទឹកជំនន់)។ | | |

**សម្គាល់៖** - *គ្រូអាចប្រើសម្ភារៈ សំណួរ និងធ្វើសកម្មភាពផ្សេងៗដើម្បីសម្រេចវត្ថុបំណងនៃមេរៀន និងធ្វើឱ្យការរៀនមានភាពសកម្ម។*

- *គ្រូវាយតម្លៃការរៀននិងបង្រៀនទៅតាមការណែនាំដូចមានក្នុងកម្មវិធីសិក្សានិងឯកសារពាក់ព័ន្ធដទៃទៀត*
- *ខ្លឹមសារមេរៀននេះចូលរួមចំណែកក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៣ ទី១៣ និងទី១៥។*

# រូបភាពជំនួយក្នុងការបង្រៀន

*ប្រភពរូបភាព:* [https://images.app.goo.gl](https://images.app.goo.gl)




រូបភាពទី១៖ គ្រោះទឹកជំនន់



រូបភាពទី២៖ គ្រោះទឹកជំនន់



រូបភាពទី៣៖ គ្រោះរាំងស្ងួត



រូបភាពទី៤៖ គ្រោះរាំងស្ងួត



រូបភាពទី៥៖ ខ្យល់ព្យុះ



រូបភាពទី៦៖ គ្រោះមហន្តរាយធម្មជាតិ

# គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

ប្រភព៖ https://csdgs.org/km/csdgs/goals




### គោលដៅទី១ ពុំមានភាពក្រីក្រ

*បញ្ចប់ភាពក្រីក្រគ្រប់ទម្រង់នៅគ្រប់ទីកន្លែង។*




### គោលដៅទី២ គ្រោះអត់ឃ្លានស្មើសូន្យ

*បញ្ចប់បញ្ចប់ភាពអត់ឃ្លាន សម្រេចឱ្យបានសន្តិសុខស្បៀង ធ្វើឱ្យប្រសើរឡើងស្ថានភាពអាហារូបត្ថម្ភ និងលើកកម្ពស់កសិកម្មប្រកបដោយចីរភាព។*




### គោលដៅទី៣ សុខភាព និងសុខុមាលភាពមាំមួន

*ធានាឱ្យជីវភាពរស់នៅរបស់ប្រជាជនប្រកបដោយសុខភាពល្អ និងលើកកម្ពស់សុខុមាលភាពរបស់មនុស្សគ្រប់រូបនិងគ្រប់វ័យ។*




### គោលដៅទី៤ ការអប់រំប្រកបដោយគុណភាព

*បញ្ចប់ធានាការអប់រំប្រកបដោយ គុណភាព បរិយាប័ន្ន និងសមធម៌ និងលើកកម្ពស់កាលានុវត្តភាពសិក្សាពេញមួយជីវិតសម្រាប់ប្រជាជនគ្រប់រូប។*




### គោលដៅទី៥ សមភាពយេនឌ័រ

*បញ្ចប់សម្រេចឱ្យបានសមភាពយេនឌ័រ និងពង្រឹងភាពអង់អាចរបស់ស្ត្រីនិងកុមារីគ្រប់រូប។*




### គោលដៅទី៦ ទឹកស្អាត និងអនាម័យ

*ធានាឱ្យមានទឹកនិងអនាម័យ និងការគ្រប់គ្រងទឹកនិងអនាម័យប្រកបដោយចីរភាពសម្រាប់ប្រជាជនគ្រប់រូប។*




## គោលដៅទី៧ ថាមពលស្អាតដែលមានតម្លៃសមរម្យ

ធានាឱ្យទទួលបានថាមពលដែលមានបច្ចេកទេសទំនើប ប្រកបដោយចីរភាព អាចជឿជាក់បាន និងមានតម្លៃសមរម្យ សម្រាប់ប្រជាជនគ្រប់រូប។




## គោលដៅទី៨ ការងារសមរម្យ និងកំណើនសេដ្ឋកិច្ច

បញ្ចប់ធានាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាប័ន្ន មានមុខរបរពេញលេញ និងផលិតភាព និងមានការងារសមរម្យ សម្រាប់ប្រជាជនគ្រប់រូប។




## គោលដៅទី៩ ឧស្សាហកម្ម នវានុវត្តន៍ និងហេដ្ឋារចនាសម្ព័ន្ធ

កសាងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងបម្រែបម្រួលអាកាសធាតុ លើកកម្ពស់ឧស្សាហូបនីយកម្មប្រកបដោយចីរភាពនិងបរិយាប័ន្ននិងលើកកម្ពស់នវានុវត្តន៍។




## គោលដៅទី១០ កាត់បន្ថយវិសមភាព

បញ្ចប់កាត់បន្ថយវិសមភាពនៅក្នុងប្រទេសនិងក្នុងចំណោមបណ្ដាប្រទេសនានា។




## គោលដៅទី១១ ទីក្រុង និងសហគមន៍ប្រកបដោយចីរភាព

ធ្វើឱ្យទីក្រុង និងទីកន្លែងតាំងទីលំនៅថ្មីសម្រាប់ប្រជាជន មានលក្ខណៈបរិយាប័ន្ន សុវត្ថិភាព ធន់នឹងបម្រែបម្រួលអាកាសធាតុនិងចីរភាព។




## គោលដៅទី១២ ការប្រើប្រាស់ និងការផលិតប្រកបដោយការទទួលខុស

ធានាឱ្យមានចីរភាពក្នុងទម្រង់នៃការប្រើប្រាស់និងផលិតកម្ម។




## គោលដៅទី១៣ សកម្មភាពបរិស្ថាន

ចាត់វិធានការជាបន្ទាន់ ដើម្បីប្រយុទ្ធប្រឆាំងនឹងបម្រែបម្រួល អាកាសធាតុ និងផលប៉ះពាល់របស់វា។




## គោលដៅទី១៤ ជីវិតក្រោមទឹក

អភិរក្សនិងប្រើប្រាស់ប្រកបដោយចីរភាពនូវ មហាសមុទ្រ សមុទ្រ និងធនធានសមុទ្រសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។




## គោលដៅទី១៥ ជីវិតលើដី

ការពារ ស្តារ និងជំរុញការប្រើប្រាស់ប្រកបដោយចីរភាពនូវប្រព័ន្ធអេកូឡូស៊ីនៅលើផែនគោក គ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព ប្រយុទ្ធប្រឆាំងនឹងឱនភាពដីបញ្ឈប់ និងបង្វែរទិសនៃការសឹករេចរឹលគុណភាពដី និងបញ្ឈប់កុំឱ្យបាត់បង់ជីវចម្រុះជាតិដីនិងជីវចម្រុះ។




## គោលដៅទី១៦ សន្តិភាព យុត្តិធម៌ និងស្ថាប័នរឹងមាំ

បញ្ចប់លើកកម្ពស់សង្គមដែលមានសន្តិភាពប្រកបដោយបរិយាប័ន្ន ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព ផ្តល់នូវការទទួលបានយុត្តិធម៌សម្រាប់ប្រជាជនគ្រប់រូបនិងកសាងស្ថាប័នដែលមានប្រសិទ្ធភាព គណនេយ្យភាព និងបរិយាប័ន្ននៅគ្រប់កម្រិត។




## គោលដៅទី១៧ ភាពជាដៃគូដើម្បីសម្រេចគោលដៅ

បញ្ចប់ពង្រឹងមធ្យោបាយអនុវត្តនានា និងបង្កើតភាពរស់រវើកនៃភាពជាដៃគូសកល សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។




## គោលដៅទី១៨ កម្ពុជាគ្មានគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម

បញ្ចប់បញ្ចប់ផលប៉ះពាល់ជាអវិជ្ជមានរបស់មីន/សំណល់ជាតិផ្ទុះពីសង្គ្រាម និងជំរុញការសង្គ្រោះជនរងគ្រោះ។

# បទានុក្រម

**កាកសំណល់:** សំដៅដល់វត្ថុធាតុ សម្ភារៈ សារធាតុ ដែលត្រូវបានគេបោះចោលបន្ទាប់ពីការប្រើប្រាស់បឋមឬគ្មានតម្លៃ និងលែងការប្រើប្រាស់។

**ការបំពុលទឹក:** ការធ្វើឱ្យកង្វក់ដល់ទឹក នៅពេលដែលសារធាតុបំពុលនានាបានហូរចូលទៅក្នុងប្រភពទឹកដោយមិនបានឆ្លងកាត់ការធ្វើប្រព្រឹត្តកម្ម (ដកយកសារធាតុបំពុលចេញ)។

**កាត់បន្ថយការបំពុលទឹក:** ការធ្វើឱ្យមានការបំពុលទឹកតិចបំផុតតាមដែលអាចធ្វើទៅបាន និងតាមវិធីសាស្ត្រផ្សេងៗ។

**ការបំពុលដី:** សំដៅលើវត្តមានសាធាតុពុលនៅក្នុងដីដែលមានកម្រិតខ្ពស់ ដែលអាចបង្កជាគ្រោះថ្នាក់ដល់សុខភាពប្រព័ន្ធអេកូឡូស៊ីលើដី ព្រមទាំងដលើសុខភាពមនុស្សជាពិសេសតាមរយៈអាហារ។

**ការបំពុលខ្យល់:** បង្កើតឡើងដោយសារធាតុគីមី ឬជីវៈសរីរាង្គ ដែលបំផ្លាញ ឬបណ្ដាលឱ្យមានផលប៉ះពាល់ដល់មនុស្ស និងភាវៈរស់មានជីវិតទាំងឡាយ និងបំផ្លាញដល់បរិស្ថានក្នុងបរិយាកាស។

**ការដុតសំរាមក្រៅឡ:** ការដុតសំរាមដោយមិនបានប្រើប្រាស់ប្រភេទឡ ដែលបង្កើតឡើងសម្រាប់ដុតសំរាម។

**ការកើនឡើងកម្តៅនៃភពផែនដី:** សំដៅលើកំណើនសីតុណ្ហភាពមធ្យមផែនដីក្នុងរយៈពេលវែង វាត្រូវបានសង្កេតថាមានកំណើនតាំងពីដើមសម័យឧស្សាហកម្ម (ឆ្នាំ១៨៥០ ដល់១៩០០) ដែលបង្កឡើងដោយសកម្មភាពរបស់មនុស្សការដុតផូស៊ីលឥន្ធនៈ ដែលនាំឱ្យមានកំណើនឧស្ម័នផ្ទះកញ្ចក់ក្នុងបរិយាកាស និងដែលខ្ទប់កម្តៅមិនឱ្យភាយចេញពីបរិយាកាសផែនដី។

**ការប្រែប្រួលអាកាសធាតុ:** សំដៅដល់ការផ្លាស់ប្ដូរច្បាស់លាស់នៅក្នុងរង្វាស់នៃអាកាសធាតុ ក្នុងរយៈពេលយូរ ឬជាការប្រែប្រួលសំខាន់ៗនៃសីតុណ្ហភាព របបទឹកភ្លៀង ព្រិល របបខ្យល់ ក្នុងរយៈពេលច្រើនទសវត្សរ៍ឬវែងជាងនេះ។

**ការបន្សាំ:** ដំណើរការសម្របខ្លួនទៅនឹងអាកាសធាតុបច្ចុប្បន្ន ឬរំពឹងទុកទៅនឹងឥទ្ធិពលនៃអាកាសធាតុ។

**ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ:** សកម្មភាពបន្សាំដែលធ្វើឡើងដើម្បីសម្របខ្លួនទៅនឹងការការប្រែប្រួលអាកាសធាតុ។

**កែច្នៃកាកសំណល់ឡើងវិញ**(5R): សំដៅដល់ការអនុវត្តវិធី ៥យ៉ាង ដើម្បីចូលរួមកាត់បន្ថយការប្រើប្រាស់បរិមាណសំណល់ជារៀងរាល់ថ្ងៃដូចជា បដិសេធមិនប្រើប្រាស់ កាត់បន្ថយការបង្កើតសំណល់ ប្រើឡើងវិញ កែច្នៃឡើងវិញ និងរំលឹកអ្នកដទៃ។

**គ្រោះមហន្តរាយធម្មជាតិ:** ព្រឹត្តិការណ៍អវិជ្ជមានពីលទ្ធផលនៃដំណើរការធម្មជាតិនៃផែនដី ដែលបណ្ដាលឱ្យខូចខាតឬបាត់បង់អាយុជីវិត។ ឧទាហរណ៍៖ ទឹកជំនន់ រាំងស្ងួត ខ្យល់ព្យុះ ព្យុះកំបុតត្បូង ផ្ទុះភ្នំភ្លើង រញ្ជួយដី រលកយក្សស៊ូណាមិ ។ល។

**គុណភាពដី:** ជាសម្ថភាពរបស់ដីដែលអាចមានដំណើរការល្អតាមលក្ខណ្ឌធម្មជាតិ ដើម្បីរក្សាផលិតភាពរុក្ខជាតិ និងសត្វ ថែរក្សា និងបង្កើនគុណភាពទឹក និងខ្យល់ ព្រមទាំងទ្រទ្រង់ដល់សុខភាព និងជម្រករបស់មនុស្ស។

**ចំហេះរថយន្ត:** ឧស្ម័នដែលចេញពីរថយន្ត ដែលជាសំណល់នៃចំណេះសាំង ឬប្រេងឥន្ធនៈ។

**ជីគីមីកសិកម្ម:** ជាជីដែលផលិតតាមបែបកែច្នៃពីសមាសធាតុគីមី ដើម្បីបង្កើនការលូតលាស់ និងផលិតផលរបស់ដំណាំ។ ជីកសិកម្មភាគច្រើន រួមផ្សំសារធាតុ នីដ្រូសែន (N) ផូស្វ័រ (P) និងប៉ាតាស្យូម (K)។

**ថង់ប្លាស្ទិក:** សំដៅដល់វត្ថុផលិតពីប្លាស្ទិកទន់អាចបត់បែនស្រួលនិងមិនងាយពុកផុយ ប្រើសម្រាប់ផ្ទុក វេចខ្ចប់ទំនិញ និងសម្ភារៈផ្សេងៗ។

**ថ្នាំពុលកសិកម្ម:** វាត្រូវបានបង្កើតឡើងតាមបែបគីមីជីវសាស្ត្រ ដើម្បីប្រើប្រាស់ក្នុងកសិកម្មសម្រាប់កម្ចាត់សត្វល្អិត ឬរុក្ខជាតិបំផ្លាញដំណាំ។

**ទីទួល ឬទីកន្លែងមានសុវត្ថិភាព:** សំដៅលើទីដែលមិនលិចទឹកនៅពេលមានទឹកជំនន់ និងមានលក្ខណអាចឱ្យមនុស្សសត្វស្នាក់នៅបានពេលមានគ្រោះមហន្តរាយធម្មជាតិ។ ទីកន្លែងមានសុវត្ថិភាពខ្លះត្រូវបានបង្កើតឡើងមុនពេលមានគ្រោះមហន្តរាយធម្មជាតិ ដោយមានត្រៀមអគារ ស្បៀងអាហារ និងសម្ភារៈជំនួយ។

**បរិស្ថានក្នុងសាលារៀន:** សំដៅលើអ្វីៗទាំងអស់ ដែលនៅមាននៅក្នុងបរិវេណសាលារៀន ឧទាហរណ៍ដូចជា ទីធ្លាសាលា អគារ ដងទង់ជាតិ សួនច្បារ ដើមឈើ បន្ទប់ទឹក កន្លែងលក់នំចំណីក្នុងសាលា។ល។

**បរិស្ថាននៅក្នុងថ្នាក់រៀន:** សំដៅលើអ្វីៗទាំងអស់ ដែលនៅមាននៅក្នុងថ្នាក់រៀន ដូចជាក្តារខៀន តុ ទូ កម្រាល សម្ភារៈលម្អថ្នាក់ ។ល។ និងរួមទាំងពន្លឺ និងខ្យល់ក្នុងថ្នាក់រៀនផងដែរ។

**បរិស្ថានក្នុងសហគមន៍:** សំដៅលើអ្វីៗទាំងអស់ ដែលនៅមាននៅក្នុងសហគមន៍ជុំវិញខ្លួនយើងទាំងមានជីវិត និងឥតជីវិត ដូចជា ខ្យល់ ទឹក ភ្លើង រុក្ខជាតិ សត្វ មនុស្ស ទន្លេ និងអ្វីៗដែលមនុស្សបានបង្កើតឡើងដូចជា លំនៅដ្ឋាន កសិដ្ឋាន។ល។

**ប្រព័ន្ធប្រកាសអាសន្ន:** បណ្តុំសមត្ថភាពដែលត្រូវការចាំបាច់សម្រាប់បង្កើត និងផ្សព្វផ្សាយព័ត៌មានប្រកាសអាសន្នឱ្យបានទាន់ពេលវេលា និងមានអត្ថន័យច្បាស់លាស់ ដើម្បីឱ្យបុគ្គលម្នាក់ សហគមន៍ និងអង្គការនានា ដែលធ្លាប់ទទួលរងការគំរាមគំហែងដោយមុខសញ្ញាគ្រោះថ្នាក់អាចត្រៀមលក្ខណៈ និងធ្វើសកម្មភាពសមស្រប ព្រមទាំងមានពេលវេលាគ្រប់គ្រាន់ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ឬការបាត់បង់ដែលអាចកើតមាន។

**ផលផ្ទះកញ្ចក់:** បាតុភូតនៃកំណើនសីតុណ្ហភាពខ្យល់នៅក្នុងលំហបិទជិតដោយកញ្ចក់ ឬកៅស៊ូប្លាស្ទិកថ្លាដែលអនុញ្ញាតឱ្យរំភាយរស្មីព្រះអាទិត្យឆ្លងកាត់ចូល តែមិនអាចឱ្យរំភាយរស្មីដែលមានជំហានរលកវែងឆ្លងកាត់ចេញវិញបាន។

**ផ្ទៃដីផលិតកម្មគ្មានជីជាតិ:** ជីវជាតិនៃដីថយចុះ ឬបាត់បង់ ដែលនាំឱ្យថយចុះនៃបរិមាណផលិតផលកសិកម្ម។

**សន្សំសំចៃថាមពលអគ្គិសនី:** ការប្រើប្រាស់ថាមពលអគ្គីសនីក្នុងទម្រង់ផ្សេងៗ ដោយប្រើប្រាស់ដោយមានប្រសិទ្ធភាព និងចាំបាច់បំផុត ឬកាត់បន្ថយការប្រើប្រាស់សម្រាប់ការដែលមិនចាំបាច់។

**សន្សំសំចៃទឹក:** ការប្រើប្រាស់ទឹកក្នុងទំរង់ផ្សេងៗ ដោយប្រើប្រាស់ដោយមានប្រសិទ្ធភាព និងចាំបាច់បំផុត ឬកាត់បន្ថយការប្រើប្រាស់សម្រាប់ការដែលមិនចាំបាច់។

**សមាសធាតុបរិយាកាសភពផែនដី:** ធាតុផ្សំនៃបរិយាកាសភពផែនដីដែលមានអាសូត($N_2$) ៧៨% អុកស៊ីសែន ($O_2$) ២១% ឧស្ម័នមួយចំនួនទៀត ១%។

**ស្រទាប់បរិយាកាសៈ** ភពផែនដីត្រូវបានចែកចេញជា៥ស្រទាប់គឺ ស្រទាប់អាកាសរចល់ ស្រទាប់អាកាសស្ងប់ ស្រទាប់អាកាសកណ្ដាល ស្រទាប់អាកាសកម្ដៅ ស្រទាប់អាកាសក្រៅ។

**សារធាតុបំពុលៈ** សំដៅទៅលើផ្សែង លំអងផ្សែង ធូលី ផេះ ភាគល្អិតនៃសំណល់ សំណល់រាវ ឧស្ម័ន ចំហាយទឹក អ័ព្ទ ក្លិន និងសារធាតុវិទ្យុសកម្ម។

**សួនជីវចម្រុះៈ** ច្បារដំណាំដែលមានរុក្ខជាតិច្រើនមុខ ក្នុងនោះមានទាំងរុក្ខជាតិរស់នៅលើគោក រុក្ខជាតិនៅក្នុងទឹក និងលើអាកាស។

**សំរាមៈ** សំដៅរបស់របរប្រើប្រាស់ សម្ភារៈ ផលិតផលដែលបានបន្សល់ឬបង្កើតពីជីវភាពផ្ទាល់របស់មនុស្សប្រចាំថ្ងៃ។

**សំណល់រាវតាមផ្ទះៈ** សំដៅដល់ទឹកសំណល់មានផ្ទុកសារធាតុបំពុលបរិស្ថានដែលបញ្ចេញពីសកម្មភាព ឬការប្រើប្រាស់តាមផ្ទះ។

**ហេដ្ឋារចនាសម្ព័ន្ធសាលារៀនៈ** ទ្រព្យដែលបានបង្កើតឡើង និងដែលអនុញ្ញាតឱ្យសាលារៀនមួយមានដំណើរការ ដូចជាអគារថ្នាក់រៀន ដងទង់ជាតិ បន្ទប់ទឹក របង ស្រះ ។ល។

**ឧស្ម័នផ្ទះកញ្ចក់ៈ** ឧស្ម័នដែលមាននៅក្នុងបរិយាកាស ដែលកើតឡើងដោយធម្មជាតិឬដោយសកម្មភាពមនុស្ស ហើយដែលស្រូបយក និងបញ្ចេញរស្មីតាមជំហានរលកជាក់លាក់ក្នុងជំហានរលកនៃរំភាយរស្មីក្រហមអាំងហ្វ្រា ដែលភាយចេញពីផ្ទៃផែនដីបរិយាកាស និងពពក។ បាតុភូតទាំងនេះបង្កឱ្យមាន ផលផ្ទះកញ្ចក់។

# ឯកសារយោង


- សៀវភៅវិទ្យាសាស្រ្ត ថ្នាក់ទី៦ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ ២០២០
- សៀវភៅ «កម្មវិធីសិក្សាការអប់រំស្តីពីការប្រែប្រួលអាកាសធាតុ» សម្រាប់បឋមសិក្សាថ្នាក់ទី៦ របស់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ឆ្នាំ២០២០
- សៀវភៅការការពារធនធានធម្មជាតិសម្រាប់មនុស្សគ្រប់គ្នា
- សៀវភៅស្តីពីការអប់រំបរិស្ថាននិងអភិរក្សសត្វក្រៀលនៃគម្រោងអភិរក្ស និងអប់រំបរិស្ថានដើម្បីជាប្រយោជន៍សត្វក្រៀល និងសហគមន៍មូលដ្ឋាន របស់អង្គការជីវិតសត្វស្លាបអន្តរជាតិប្រចាំនៅកម្ពុជា (Birdlife International Cambodia Programme)
- អ្វីទៅជាបរិស្ថាន? https://www.khsearch.com/qna/10528
- ចំណេះដឹងទូទៅ https://www.khsearch.com/qna/8284
- ថាមពលកំដៅផែនដី https://thmeythmey.com/?page=detail&id=79087
- ឯកសារអប់រំស្តីពីការប្រែប្រួលអាកាសធាតុ សម្រាប់មធ្យមសិក្សាទុតិយភូមិ ឆ្នាំ២០១៨ របស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងបរិស្ថាន
- សៀវភៅជំនួយស្មារតីស្តីពីការប្រែប្រួលអាកាសធាតុសម្រាប់មធ្យមសិក្សាបឋមភូមិ ឆ្នាំ២០១៩ របស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងបរិស្ថាន
- https://makmaklifestyle.wordpress.com/2018/05/17/
- ប្រភពទឹក: https://www.usgs.gov/special-topic/water-science-school/science/where-earths-water?qt-science_center_objects=0#qt-science_center_objects និង ប្រភពដើម Igor Shiklomanov's chapter "World fresh water resources" in Peter H. Gleick (editor), 1993, Water in Crisis: A Guide to the World's Fresh Water Resources (Oxford University Press, New York).
- https://opendevelopmentcambodia.net /km/topics/adaptation/
- https://opendevelopmentcambodia.net/km/topics/disasters-and-emergency-response/
- www.humanitarianresponse.info/files/documents/files/khm0301_safesiteguide_kh_0.pdf

CAMBODIA CLIMATE CHANGE ALLIANCE

Implemented by:

Funded by:

Empowered lives.
Resilient nations.

ស៊ុយអែត
Sverige